# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះទេពសត្ថា សូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

| | | |
|---|---|---|
| *ផ្នែកអក្សរសាស្ត្រ* | | ទំព. |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ពាក្យថ្មីៗ ក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ....... | ២[illegible] |
| — | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តមក).. | ២៥៥ |
| អ្នកឧកញ៉ា ឈិម-ក្រសេម | ព្រះរាជពង្សាវតារភាគទី ១ សម័យនគរភ្នំ (តមក). | ២៦២ |
| លោក ភិយ-ប៊ុត ក្រមការ | សុភាសិតខ្មែរ ភាគទី ១ (តមក) ........... | ២៧១ |
| — | ប្រជុំពាក្យព្រេងនិងបាវចនាបារាំង (តមក)..... | ២៧៨ |
| លោកអាចារ្យ និញ-ប្រាជ្ញ | រឿងធ្វើស្រែខ្មែរ នៅកម្ពុជាក្រោម (ក្វស៊ាងស៊ីន) (តមក-ចប់) ........................ | ២៧៩ |
| អ្នកឧកញ៉ាព្រះឃ្លាំង ឧង | រឿងរាជកុលកុមារ (តមក) ............ | ២៨៦ |
| *ផ្នែកសាសនា* | | |
| ព្រះសពមហារស់-កោ | សាបត្តិកថា ........................... | ២៩៣ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក ថែម | ពន្ធអាស៊ីទិប (តមក)..................... | ៣០៦ |
| *កំណត់នៃប្រវត្តិការណ៍* | | |
| ភិក្ខុ សួន-ស៊ីន | បុណ្យឈាបនកិច្ចសពអ្នកអាចារ្យ ហ៊ុន-សុធី . | ៣១២ |
| ក្រសួងធម្មការ | អំពីការតាំងហៅអធិការថ្មី (តមក) .......... | ៣១៨ |

ឆ្នាំទី ២១ — លេខ ៤ ខែមេសា ឆ្នាំ ១៩៤៩ — ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ។

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Satthā So-Hay membre de la Commission du Tripitaka

## TABLE DES MATIÈRES

### Partie littéraire

| | | page |
|---|---|---|
| Luong Nibandhamantrî Nhok-Thèm | Nouveaux terme de législation employé dans la Constitution .......... | 244 |
| — d.— | Histoire sommaire de l'Inde (suite). | 255 |
| Neak Oknha Chhim-Krasem Député | Histoire ancienne du Camdodge (suite). | 262 |
| M. Ray-Buc kramakar (I. B.) | Proverbes et maximes tome I (suite). | 271 |
| —id— | Recueil de Dictons et devises français (suite)...................... | 275 |
| Monsieur Dinh-Prach | Travaux des champs chez les Cambodgiens de Cochinchine (suite et fin).. | 279 |
| Feu Neak Oknha Brah khleang Nong | Bhog kul kumār (suite) .......... | 286 |

### Partie religieuse:

| | | |
|---|---|---|
| Feu Vén. Ros-Ko | Samaggikathā.................. .... | 293 |
| Luong Nibandhamantri Nhok-Thêm | Lumière de l'Asie (suite).......... | 306 |

### Notes et chroniques

| | | |
|---|---|---|
| Vén. Suon Surin | Compte-rendu des cérémonies de la crémation de l'Achar Hin-Such ...... | 312 |
| Ministère des cultes | Nomination des nouveaux chau Adhikar (suite)................... | 318 |

...née: N° 4 Avril 1949 — Prix d'abonnement 96$00 par an.

# ពាក្យប្រារព្ធ

ការនាំយកពាក្យថ្មីៗ ព្រមទាំងសេចក្ដីអធិប្បាយមកចុះផ្សាយក្នុងកម្ពុជសុរិយានេះ យើងយល់ថា មានប្រយោជន៍ដល់អ្នកអានទស្សនាវដ្ដីរបស់យើងខ្ញុំទៅ ព្រោះជាបច្ច័យឲ្យវិវត្តចំណោះខាងផ្នែកអក្សរសាស្ត្ររីកចំរើនឡើងតាមកាលសម័យ ៗ ក្នុងឱកាសនេះ យើងស្រង់យកពាក្យថ្មីៗខ្លះអំពីរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជាដែលលោក អៀវ-កើស ប្រធានរដ្ឋសភា បានប្រមូលអធិប្បាយទុកនៅខាងចុងច្បាប់រដ្ឋធម្មនុញ្ញយកមកចុះផ្សាយក្នុងទីនេះទៀត គ្រាន់តែផ្លាស់វិធីរៀបរៀងជាថ្មី គឺក្នុងទីនេះ ប្រើពាក្យបារាំងជាមេពាក្យ ហើយទើបប្រែជាខ្មែរ បន្តសេចក្ដីពន្យល់ ឬសេចក្ដីអធិប្បាយនៅខាងចុង ។

ការដែលយើងរៀបរៀងតាមវិធីនេះ ដើម្បីត្រូវតាមពាក្យថ្មីផ្សេងៗទៀត ដែលគណកម្មការវប្បធម៌បានប្រែរួចហើយ យើងនឹងយកមកចុះផ្សាយក្នុងទស្សនាវដ្ដីនេះតាំងពីដំបូងតរៀងទៅ ។

អស់លោក-អ្នកដែលស្រឡាញ់ពេញចិត្តនឹងប្រទេសជាតិ គង់ជ្រាបជាក់ច្បាស់ថា ភាសានិងអក្សរជាគ្រឿងឧបករណ៍យ៉ាងសំខាន់ក្នុងនយោបាយការពារប្រទេសជាតិមិនឲ្យរលាយសាបសូន្យ ។ ហេតុនេះ ហើយបានជាការៈប្រទេសទាំងឡាយ ទាំងតូច ទាំងធំ ខំខិតបំរុង ខំពង្រីកភាសានិងអក្សរសាស្ត្ររបស់ជាតិគេយ៉ាងម៉ឺងម៉ាត់ ដើម្បីជា

កិត្តិយសរបស់ប្រទេសជាតិគេផង ជានយោបាយផ្សាយឥទ្ធិពលរបស់ជាតិគេផង ។

តាមដែលយើងបានសង្កេតឃើញនូវការណ៍គួរឲ្យចាប់អារម្មណ៍នេះ យល់ថាជនជាតិខ្មែរយើងហាក់ដូចជាមិនសូវយកចិត្តទុកដាក់នឹងអក្សរសាស្ត្ររបស់ជាតិទេ មានភាគតិចណាស់ ដែលយកចិត្តទុកដាក់ជួយទំនុកបំរុងភាសានិងអក្សររបស់ជាតិខ្លួន ។ ហេតុនេះ បានជាសៀវភៅបោះពុម្ពនិងកាសែតផ្សេងៗជាភាសាខ្មែរចំរើនឡើងពុំរួច ។ សព្វថ្ងៃនេះកាសែតនិងសៀវភៅបោះពុម្ពជាភាសាខ្មែរមានចំនួនមួយស្តើងណាស់មិនសមនឹងឋានៈរបស់ប្រទេស និងចំនួនប្រជាជនខ្មែរ ។ ពិតមែនតែពេលកន្លងនេះ យើងខ្វះអក្សរ ខ្វះម៉ាស៊ីនបោះពុម្ព ពីមុននេះបន្តិចខ្វះក្រដាសបោះពុម្ពថែមទៀតផង ។ តែដល់មកសព្វថ្ងៃនេះ បញ្ហាខ្វះក្រដាសបោះពុម្ពមិនសូវសំខាន់ទេ ព្រោះក្រដាសមានហៀរហូរល្មមស្រុកយើងគ្រប់គ្រាន់ហើយ នៅខ្វះតែអក្សរនិងម៉ាស៊ីនប៉ុណ្ណោះ ។ បញ្ហាខាងក្រោមនេះ បើយើងប្រឹងរកមធ្យោបាយដោះស្រាយដោយម៉ឹងម៉ាត់ក៏គង់តែសម្រេចដោយងាយពុំខាន ។ បញ្ហាការខ្វះខាតឯងដទៃទៀត ដូចសំពត់, អំបោះ, ស្ករ, ឈើគូសជាដើម ផុតលេចអស់ទៅហើយ ដោយការស្រាយសេចក្តីខ្វល់ខ្វាយនៃពួកឈ្មួញ ។ ឯរឿងអក្សរនិងម៉ាស៊ីនបោះពុម្ពក៏គង់មានថ្ងៃដូចគ្នាដែរ ។

ទៅទីបំផុត យើងសូមរំលឹកបងប្អូនរួមជាតិ ដោយមេត្រីចិត្តសុចរិតស្មោះត្រង់ថា « តែបណ្ដោយឲ្យអក្សរនិងភាសារលំ ជាតិយើងមុខជារលាយ » ។ ហេតុនេះ, យើងត្រូវព្រួតដៃគ្នាកសាងភាសាអក្សររបស់យើងឲ្យបានល្អលាស់ឡើងតាមកាលសម័យ ដើម្បីជាបច្ច័យឲ្យជាតិ-សាសនា-មហាក្សត្រ និងរដ្ឋធម្មនុញ្ញរបស់យើងគង់នៅខ្ជាប់ខ្ជួនតទៅ ។

ញ៉ុក-ថែម

# ពាក្យប្រែនិងពាក្យអធិប្បាយ

## (ស្រង់ពីរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជា)

---

Accord កិច្ចព្រមព្រៀង គឺលិខិតសញ្ញាដែលមានសារៈសំខាន់ តិចជាងសន្ធិសញ្ញា និងអនុសញ្ញា ហៅថា កិច្ចព្រមព្រៀង ។ ១. តាំងពីផុតមហាសង្គ្រាមលើកក្រោយនេះមក ប្រទេសកម្ពុជាបានធ្វើកិច្ចព្រមព្រៀងនឹងប្រទេសបារាំងអស់ ៩ កិច្ច ។

Assemblée Ordinaire ប្រជុំសាមញ្ញ: ប្រជុំតាមធម្មតា ។ ១. រដ្ឋសភាមានសម័យប្រជុំសាមញ្ញ ២ ក្នុងមួយឆ្នាំ ។ សម័យប្រជុំនីមួយៗ មានកំណត់វេលាយ៉ាងតិច ៣ ខែ ។ ដល់ផុតសម័យប្រជុំនីមួយៗ អ្នកតំណាងរាស្ត្រឈប់សម្រាកទៅវិលទៅវេន ។ ១៨ ។

Assemblée extraordinaire ប្រជុំវិសាមញ្ញ: ប្រជុំខុសពីធម្មតា ។ ១. កាលណាផុតសម័យប្រជុំសាមញ្ញនីមួយៗ អ្នកតំណាងរាស្ត្រតែងបានឈប់សម្រាកតាមកំណត់ធម្មតា ។ បើក្នុងពេលត្រូវឈប់សម្រាកនេះ ដូចជាមានការចាំបាច់កើតឡើង ត្រូវហៅរដ្ឋសភាមកប្រជុំ សម័យប្រជុំបែបនេះ ហៅថា ប្រជុំវិសាមញ្ញ ។

Autonomie : ស្វ័យភាព: ការគ្រប់គ្រងប្រទេសដោយខ្លួនឯង ។ រដ្ឋស្វ័យភាព ជាប្រទេសដែលមានអំណាចគ្រប់គ្រងនូវប្រទេសដោយ

ខ្លួនឯង គឺជាមានតែអំណាចអធិបតេយ្យខាងក្នុងប្រទេស ឯអំណាចអធិប-តេយ្យខាងក្រៅប្រទេស ត្រូវជាការៈរបស់រដ្ឋឯកបត្យមួយផ្សេងទៀត ។

Budget : ថវិកា ។ ពាក្យនេះ លើប្រែតាមរូបសព្ទថាថង់ (ថង់ប្រាក់) ត្រូវនឹងពាក្យបារាំង ប៊ុតសេ, សំដៅដល់តារាងប្រាក់ចំណូល - ចំណាយ ។

Capacité : សមត្ថភាព គឺភាពនៃបុគ្គលដែលអាចធ្វើបាន ។ ១. ខ្ញុំមានចំណេះចេះធ្វើទូ, តុ, កៅអីបាន ហើយខ្ញុំមានកំឡាំងនិងនឹងគ្រឿងប្រដាប់ល្មមនឹងធ្វើការនេះកើត គេថាខ្ញុំមានសមត្ថភាពធ្វើប្រដាប់ប្រដានេះបាន ។ បើខ្ញុំធ្វើមិនកើត គេថាខ្ញុំគ្មានសមត្ថភាពទេ ។

Cas : ករណី : ការដែលកើតឡើង: ហេតុដែលបណ្ដាលឡើង, រឿងដែលមានឡើង ។

Citoyens : ពលរដ្ឋ គឺសមាជិករបស់រដ្ឋ គឺជនដែលមានសិទ្ធិពេញតាមច្បាប់សម្រាប់ស្រុក ។ ១. ក្នុងប្រទេសខ្មែរ ជនជាតិខ្មែរនិងជនជាតិដែលកប់ជាខ្មែរ ដូចជា ចាម កួយ ពន សំរែ.. និងជនដែលចូលជាតិជាខ្មែរ ជាពលរដ្ឋខ្មែរ ។ ឯជនជាតិក្រៅអំពីនេះដូចចិន យួន ភ្នងជាដើម មិនមែនជាពលរដ្ឋខ្មែរទេ ។ ជនពួកក្រោយនេះខ្វះសិទ្ធិខ្លះ ដូចជាសិទ្ធិបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រជាដើម ។

Condition: លក្ខណសម្បត្តិ : សំដៅដល់លក្ខណបុគ្គលដែលត្រូវមាន ដើម្បីឲ្យមានសិទ្ធិជ្រើសតាំងឬដើម្បីឈរឈ្មោះជាបេក្ខជន ។ លក្ខណសម្បត្តិដែលត្រូវមានដើម្បីតាំងអ្នកតំណាងរាស្ត្របាននោះ គឺជាពលរដ្ឋខ្មែរ ភេទប្រុស អាយុមិនតិចជាង ២០ ឆ្នាំបរិបូណ៌ ពុំមែនជាទាហានពុំមែនជាបព្វជិត ពុំមែនជាមនុស្សវិកលចរិត ឬមនុស្សមានទោសទណ្ឌ ។ល។ (ពាក្យ Condition នេះគួរនឹងប្រែថា លក្ខខណ្ឌ ក៏បាន) ។

Conseil des Ministre: គណៈរដ្ឋមន្ត្រី: ក្រុមរដ្ឋមន្ត្រីទាំងអស់គ្នា រួមបញ្ចូលរដ្ឋលេខាធិការផង ។

Conseil du Royaume: ក្រុមប្រឹក្សាព្រះរាជាណាចក្រ គឺប្រជុំឬសភាមួយ ចំនួនប្រហែលគ្នានឹងរដ្ឋសភាដែរ តែរដ្ឋសភាកាន់អំណាចនិតិបញ្ញត្តិ ។ ឯសភានេះមិនកាន់អំណាចនិតិបញ្ញត្តិទេ គ្រាន់តែពិនិត្យច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិតាំងហើយ និងបញ្ហាដែលរដ្ឋសភាបានបញ្ជូនមកឲ្យពិនិត្យ ។

Candidat: បេក្ខជន គឺអ្នកឈរឈ្មោះឲ្យគេជ្រើសតាំងខ្លួន គឺជាជនណាមួយមានបំណងចង់ធ្វើជាតំណាងរាស្ត្រ ហើយបានឈរឈ្មោះឲ្យរាស្ត្រ បោះឆ្នោតជ្រើសតាំងខ្លួនឡើង ។

Convention: អនុសញ្ញា : លិខិតសញ្ញាដែលមានសារៈសំខាន់ជាងពីសន្ធិសញ្ញា ។ ឧ. ប្រទេសកម្ពុជាបានធ្វើអនុសញ្ញាជាមួយនឹងប្រទេសបារាំង នៅ គ.ស. ១៨៨៤ ។

Colonie: អាណានិគម ឬប្រទេសអាណានិគម គឺប្រទេសចំណុះ ឬប្រទេសដែលនៅក្រោមបង្គាប់ប្រទេសដទៃ ។ ឧ. ប្រទេសកូស័ងស៊ីន មុនពេលសង្គ្រាមលើកក្រោយនេះ មិនមែនជារដ្ឋយៀតណាមទេ ព្រោះគ្មានរដ្ឋាភិបាល គឺជាប្រទេសអាណានិគមបារាំង ។

Cruauté: ទារុណកម្ម គឺអំពើកាច, អំពើសាហាវ ឬអំពើអាក្រក់ ។ កងទ័ពនេះ បានដល់ការដាក់តំណៅយ៉ាងតឹងតែងឥតមេត្តា ។

Devoir: ករណីយកិច្ច ការអ្វីៗដែលយើងត្រូវធ្វើ ។ ឧ. សេចក្តីគោរព ជាករណីយកិច្ចនៃបុត្រ ចំពោះមាតា-បិតា ប្រែសេចក្តីថាបុត្រត្រូវតែគោរពមាតា-បិតា ។ ការបង់ពន្ធជូនរដ្ឋការ ជាករណីយកិច្ចនៃពលរដ្ឋទាំងឡាយ ។

Discipline: វិន័យ គឺរបៀបច្បាប់ទាំងពួង ដែលមនុស្សទាំងឡាយនៅក្នុងក្រុម ក្នុងពួកជាមួយគ្នាត្រូវប្រតិបត្តិតាម ។

Evénement: ព្រឹត្តិការណ៍ គឺហេតុដែលបណ្តាលកើតឡើងក្នុងលោក, ហេតុដែលគួរសំគាល់បាន ។

Etat : រដ្ឋ គឺប្រទេសឬដែន ដែលមានរដ្ឋាភិបាលឬរាជរដ្ឋាភិបាលគ្រប់គ្រង ។

Etat Associé : សមាគតរដ្ឋ គឺរដ្ឋដែលនៅក្នុងសហភាពបារាំង ។ សហភាពបារាំង ទុកដូចជាក្រុមហ៊ុនមួយ ឬសមាគមមួយ ។ រដ្ឋដែលនៅក្នុងសហភាពបារាំង ទុកដូចអ្នកចូលហ៊ុនក្នុងសមាគម ទើបហៅថា សមាគតរដ្ឋ ។

Egalité : សមភាពគឺភាពស្មើគ្នា ។ ខេមរជនមានសមភាពដូចគ្នា ប្រែសេចក្ដីថា ខេមរជនមានសិទ្ធិ គ្មាននរណាមានសិទ្ធិច្រើនជាងនរណាទេ ។

Gouvernement : រដ្ឋាភិបាល គឺនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទាំងឡាយ ព្រមទាំងរដ្ឋលេខាធិការផង រួមគ្នាទាំងអស់ជារដ្ឋាភិបាល ។

Grades: ឋានន្តរស័ក្តិ គឺបណ្ដាស័ក្តិតូច-ធំតាមមុខការ ។

Immunité (Parlementaire) អភ័យឯកសិទ្ធិ គឺសិទ្ធិដែលជនខ្លះមានចំពោះខ្លួនម្នាក់ៗ មិនឲ្យមានភ័យ មិនឲ្យមានទោសដល់ខ្លួន ដូចមិនឲ្យគេចោទ គេចាប់ គេឃុំឃាំងជាដើម ដោយហេតុបានសំដែងយោបល់ ឬបញ្ចេញមតិដូច្នេះ ដូច្នោះ ក្នុងមុខក្រសួងរបស់ខ្លួន ។ អភ័យឯកសិទ្ធិនេះ ជារបស់សមាជិករដ្ឋសភា ។

Journal Officiel រាជកិច្ច គឺជាសែតរាជការ ។ ក្នុងទីនេះ សំដៅដល់ទស្សនាវដ្ដី ដែលរាជការបានបោះពុម្ព ចុះកិច្ចរាជការផ្សេងៗដូចជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា ។ល។ ដើម្បីផ្សាយដល់មហាជន ។

Législation : នីតិកាល គឺរយៈពេលនៃរដ្ឋសភា កប់តាំងពីពេលប្រជុំដំបូង រហូតដល់ពេលដែលត្រូវរំលាយ ដើម្បីឲ្យប្រជារាស្ត្រជ្រើសតាំងជាថ្មី ។ តាមធម្មតា នីតិកាលនៃរដ្ឋសភាខ្មែរមានកំណត់ ៤ ឆ្នាំ ។

Majorité: និតិភាព គឺភាពនៃជនដែលមានអាយុពេញការតាមច្បាប់ហើយ. សម្រាប់ជនជាតិខ្មែរ កំណត់អាយុដែលអាចប្រើសិទ្ធិរបស់ខ្លួនដោយពេញបរិបូណ៌បាន គឺអាយុ ២០ ឆ្នាំ ។

Mandat អាណត្តិ: សេចក្ដីបង្គាប់ ។ ក្នុងទីនេះសំដៅដល់សិទ្ធិដែលប្រជារាស្ត្រប្រគល់ទៅជនណាមួយឲ្យនិយាយការជួសខ្លួន ។

Membre: សមាជិក គឺអ្នកចូលក្នុងសមាគម ឬអ្នកកប់បញ្ចូលក្នុងពួកក្រុមណាមួយ ។ ឧ. ក្នុងគ្រួសារមួយមានគ្នា ៧ នាក់ គឺជីតា ជីដូន, ឪពុក, ម្ដាយ និងកូន ៣ នាក់ ។ មនុស្សទាំង ៧ នាក់នេះ ជាសមាជិកនៃគ្រួសារនោះ គឺជីតាជាសមាជិក ១ ជីដូនជាសមាជិក ១ ។ ល ។ អ្នកតំណាងរាស្ត្រជាសមាជិកនៃរដ្ឋសភា ។

Ministre រដ្ឋមន្ត្រី: អ្នកកាន់អំណាចនីតិប្រតិបត្តិ, កាលពីសម័យមុននេះ គេហៅថា សេនាបតី ។

Minorité អនីតិភាព គឺភាពនៃកូនដែលមានអាយុមិនទាន់ពេញការតាមកំណត់ច្បាប់ ។ សម្រាប់ជនជាតិខ្មែរ សំដៅដល់កូនដែលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំបរិបូណ៌ ។

Motion ញត្តិ: ពាក្យដែលស្នើប្រកាសក្នុងប្រជុំ ។ សេចក្តីណែនាំដែលសមាជិកផ្ដេសកាបានថ្លែងក្នុងប្រជុំ ។

Nation: ប្រជាជាតិ: មនុស្សទាំងឡាយដែលនៅរួបរួមក្រោមអំណាចបជការតែមួយដូចគ្នា ហើយត្រូវប្រតិបត្តិតាមច្បាប់មួយដូចគ្នា ហៅថា ប្រជាជាតិមួយ ។

Ordre Royal du Cambodge: គ្រឿងឥស្សរិយយសកម្ពុជា ។ គ្រឿងនេះគេបង្កើតឡើង ដើម្បីឲ្យចំណាប់ដល់ជនដែលបានប្រព្រឹត្តល្អ បានធ្វើប្រយោជន៍ដល់ពលការ ដល់ប្រទេសជាតិ មានប្រភេទផ្សេងៗ គឺគ្រឿងឥស្សរិយយសសុវត្ថាណ បំណាច់ខាងក្សេត្រាធិការ (Ordre du Mérite Agricole) គ្រឿងឥស្សរិយយសមុនីសារភ័ណ្ឌ (Ordre du Mérite Historique, Littéraire et Seientifique) គ្រឿងឥស្សរិយយសព្រះករុណាទ្រង់ពស្យ (Ordre du Règne) គ្រឿងឥស្សរិយយសស្ត្រីវឌ្ឍនា (Ordre du Mérite Féminin) គ្រឿងឥស្សរិយយសកីឡាបុទ្ធ (Ordre du mérite Sportif)

កូនក្រុមឥស្សរិយយសនីមួយៗមានថ្នាក់ផ្សេងៗដូចជាឥស្សរិទ្ធ (chevalier) សេនា (Officier) ធិបឌិន (Commandeur) មហាសេនា (Grand Officier) មហាសិរីវឌ្ឍន៍ (grand Croix) ទាំងអស់ ៥ ថ្នាក់ ។ ក្រុមឥស្សរិយយសខ្លះមានតែ ២ ឬ ៣ ថ្នាក់ ។ មនុស្សក្នុងថ្នាក់នីមួយៗ នៃក្រុមឥស្សរិយយសមានគ្រឿងឥស្សរិយាភរណ៍ពាក់ជាសំគាល់ ។ គ្រឿងឥស្សរិយាភរណ៍ហៅតាមពាក្យសាមញ្ញថា «ម៉េដាយ» ។

Président : ប្រធាន: អ្នកដែលធំជាងគេក្នុងកិច្ចប្រជុំ ។ ដូចកាលហៅ-ថា អធិបតី ក៏បាន ។

Président du Conseil des ministres : នាយករដ្ឋមន្ត្រី: រដ្ឋមន្ត្រីដែលជាធំជាងរដ្ឋមន្ត្រីដទៃទៀត ដែលជានាយនៃរដ្ឋមន្ត្រីដទៃទៀត ។ ត្រូវនឹងពាក្យថា «អគ្គមហាសេនា» ដែលធ្លាប់ប្រើក្នុងសម័យមុននេះ ។

Prince héritier : រជ្ជទាយាទ គឺព្រះអង្គម្ចាស់ ដែលត្រូវទទួលរាជ-សម្បត្តិជាមរតក, ក្សត្រដែលបំរុងគ្រងរាជ្យជាតំណអំពីក្សត្រដែលគង់ក្នុងរាជសម្បត្តិ ។

Personne morale : នីតិបុគ្គល គឺបុគ្គលនេះគ្មានរូបគ្មានអង្គទេ ។ នីតិបុគ្គលនេះហើយដែលជារដ្ឋ (Etat) ។

Obstacle : ឧបសគ្គ គឺ គ្រឿងទើសទាក់, គ្រឿងជំពាស់, គ្រឿងរាំង ។

Pouvoir judiciaire: អំណាចតុលាការគឺអំណាចជំនុំជំរះក្តី ។

Pouvoir législatif: អំណាចនីតិបញ្ញត្តិ: អំណាចធ្វើច្បាប់ - តាំង-ច្បាប់-រៀបចំធ្វើច្បាប់ ។

Pouvoir exécutif: អំណាចនីតិប្រតិបត្តិ: អំណាចប្រើច្បាប់ដែលតាំងទុកមកហើយ, អំណាចយកច្បាប់ទៅដាក់ឲ្យប្រជាជនប្រតិបត្តិតាម ។

Profession: វិជ្ជាជីវៈ: អាជីវៈគឺ របរមុខការរកស៊ី ។ វិជ្ជាជីវៈ: គឺអាជីវៈ ដែលត្រូវប្រើវិជ្ជា បានដល់របរដែលត្រូវប្រើចំណេះដឹង ដូចពេទ្យ, គ្រូអាចារ្យ ជាដើម ។

Règlement: បទបញ្ជា: សារបង្គាប់បញ្ជា ឬ សេចក្តីបង្គាប់បញ្ជា ។

Région: ភូមិភាគ: ចំណែកមួយនៃផែនដី ឬជាចំណែកនៃប្រទេស, មិនមែនប្រទេសទាំងមូលទេ ។

Règne: រជ្ជកាល: គឺរយៈ វេលាដែលព្រះមហាក្សត្រឋិតនៅក្នុងរាជសម្បត្តិ ។

Ratification: សច្ចាប័ន: ការបញ្ជាក់ត្រឹមត្រូវតាមរបៀបច្បាប់នូវរបស់ដែលបានធ្វើហើយ ឬដែលបានសន្យានឹងគ្នាហើយ ។

Régent: រាជានុសិទ្ធ គឺអ្នកដែលទទួលព្រះរាជការៈ គ្រងរាជ្យ ជំនួសក្សត្រ ក្រែងកាលជាបណ្តោះអាសន្ន ។

Spécial: ប្លែក, ដោយឡែក ។

Secrétaire d'Etat : រដ្ឋលេខាធិការ មានមុខក្រសួងដូចរដ្ឋមន្ត្រីដែរ តែកាន់ការមានសារៈសំខាន់តិចជាង ។

Suffrage restreint: អសាកល មិនមែនទាំងអស់ មិនមែនទាំងមូល បោះឆ្នោតអសាកល គឺបោះឆ្នោតមិនទាំងអស់គ្នា ជនខ្លះមានសិទ្ធិបោះឆ្នោត ជនខ្លះគ្មាន ។ ដូចជាក្នុងការជ្រើសតាំងទីប្រឹក្សាព្រះរាជអាណាចក្រមួយនាក់ ដែលជាអ្នកតំណាងអ្នកជំនួញស្រុក មានតែអ្នកជំនួញស្រុកប៉ុណ្ណោះទេ ដែលមានសិទ្ធិបោះឆ្នោតបាន ។ ឯជនមិនបានធ្វើជំនួញស្រុក ធ្វើតែជំនួញឯទៀត ឬមិនបានធ្វើជំនួញទេ នោះគ្មានសិទ្ធិបោះឆ្នោតជ្រើសតាំងទីប្រឹក្សាព្រះរាជអាណាចក្រនេះបានទេ ។

Traité: សន្ធិសញ្ញា គឺលិខិតសញ្ញាដែលប្រទេសមួយបានធ្វើនឹងប្រទេសមួយទៀត ដើម្បីឲ្យមានការទាក់ទងភ្ជាប់គ្នាទៅវិញទៅមក ។ សន្ធិសញ្ញានេះ ជាលិខិតសញ្ញាដែលមានសារៈសំខាន់ជាងលិខិតសញ្ញាដទៃទៀត ។ ឧ. ប្រទេសកម្ពុជា បានធ្វើសន្ធិសញ្ញាមួយជាមួយនឹងប្រទេសបារាំងនៅ គ.ស. ១៨៦៣ ។

Union française : សហភាពបារាំង : ការរួបរួមជាមួយនឹងប្រទេសបារាំង ។ ឧ. ប្រទេសបារាំងនៅអឺរ៉ុប ខេត្តបារាំងនិងដែនដីបារាំងឯនាយសមុទ្រ នេះជាផ្នែកមួយ ។ ដែនដីសមាគត ឬសមាគតរដ្ឋ នេះជាផ្នែកមួយទៀត រួមគ្នាទៅហៅថា សហភាពបារាំង ។

Universel : សាកល: ទាំងអស់ ទាំងមូល ។ ឧ. បោះឆ្នោតសាកល គឺបោះឆ្នោតទាំងអស់គ្នា គឺពលរដ្ឋគ្រប់រូបអាចបោះឆ្នោតបានទាំងអស់គ្នា ឲ្យតែមានលក្ខណសម្បត្តិគ្រប់គ្រាន់ ។

Volonté : ឆន្ទ : គឺសេចក្តីគាប់ចិត្ត សេចក្តីប្រាថ្នា បំណងយ៉ាងមុតមាំ ។

Voix : មតិ : សេចក្តីយល់, យោបល់ ។

---

(3)

# ប្រវត្តិសាស្ត្រខ្មែរសង្ខេប

## ហ្លួងគិតខ្លួមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

(តមក)

ប្រសិនបើមិនមានទំនងផ្ទុះទេ ទ្រង់គង់មិនទំនុកបំរុងសាសនាព្រាហ្មណ៍ឡើយ ។

ក្រៅពីលទ្ធិសាសនាព្រាហ្មណ៍ នៅមានលទ្ធិសាសនាដទៃៗទៀត ហើយមានគណាចារ្យកាន់កាប់រក្សាប្រដៅខ្លួន ព្រះបាទអសោកក៏មិនទ្រង់បៀតបៀនយ៉ាងណាទេ គ្រាន់តែទ្រង់សំដែងព្រះពុទ្ធបំណងឲ្យម្ចាស់សាសនានោះៗ នាំគ្នាជួយទំនុកបំរុងសីលធម៌របស់ប្រជាជន ។ ព្រះតម្រិះនេះទ្រង់បានចារិកទុកលើផ្ទាំងសិលា ហើយនាំទៅប្រតិស្ឋានទុកក្នុងតំបន់ផ្សេងៗ សិលាចារិកអស់នោះ នៅមានគង់ទ្រង់ហូតមកដល់សម័យនេះ មានសិលាចារឹក ១ ផ្ទាំងនោះ សឲ្យឃើញបរិយាវគ្គដ៏ប្រពៃរបស់ព្រះបាទអសោកមហារាជដូចមានសេចក្តីបែបខាងក្រោមនេះ :

« រាស្ត្រគ្រប់គ្នាជាកូនរបស់ខ្ញុំ ខ្ញុំត្រូវការឲ្យកូនក្នុងខ្លួនរបស់ខ្ញុំប្រកបដោយសុខសួស្តីក្នុងលោកនេះត្រឹមណា ខ្ញុំក៏ប្រាថ្នាឲ្យរាស្ត្រមានសេចក្តីសុខសួស្តីត្រឹមណោះដែរ ។ ខ្ញុំបានដាំដើមឈើនៅក្បែរផ្លូវ ដើម្បីឲ្យមានម្លប់ត្រជាក់ដល់មនុស្សនិងសត្វ ។ ខ្ញុំបានដាំចម្ការស្វាយ ជីកស្រះសង់សាលា សម្រាប់ជាទីស្នាក់របស់មនុស្សនិងសត្វ ។ ខ្ញុំតាំងអ្នក

ថេរវាទសាសនា សម្រាប់ធ្វើការកុសលផ្ចប់ប្រគេនហើយប្រតិបត្តិតាម របស់សាសនាគ្រប់និកាយ ។ ហើយខ្ញុំយកចិត្តទុកដាក់និងព្រះសង្ឃរបស់ ព្រះពុទ្ធសាសនា ហើយសូម្បីពួកព្រាហ្មណ៍ដែលកាន់សាសនារបស់ពួក សុំតាន និងលទ្ធិសាសនាដទៃៗទៀត ខ្ញុំក៏យកចិត្តទុកដាក់ដែរ" ។

កាលពុទ្ធសករាជ ៣០១ នោះ ព្រះបាទអសោកទ្រង់តាក់តែងឲ្យមាន សង្គាយនាជាគ្រាទី ៣ នៅក្រុងបាដលីបុត្រ ដែលជាទីក្រុងរបស់ព្រះ អង្គ ។ ការប្រជុំធ្វើសង្គាយនាគ្រានេះ មានព្រះសង្ឃមកប្រជុំចំនួន ពាន់អង្គហើយនៅគ្រានេះឯង ដែលសម្រេចថាត្រូវតែបញ្ជូនគណៈ ធម្មទូតឲ្យចេញទៅប្រកាសព្រះសាសនាក្នុងទិសានុទិស គឺព្រះមហា. រក្ខិត ត្រូវទៅប្រកាសព្រះសាសនាខាងខែត្រដែនក្រិក ព្រះមជ្ឈន្តិកៈ ទៅប្រកាសខាងស្រុកកស្មីរៈ និងដែនគន្ធារៈ ព្រះមហាធម្មៈ និងព្រះ មហាទេវៈ ទៅប្រកាសខាងកាណាបក្រុងបទេស ។ ខាងក្នុងហិមាល័យ ព្រះមហាធម្មៈ ទៅប្រកាសខាងខែត្រដែនមហាក្រដ្ឋ ព្រះមហាទេវៈ ទៅប្រកាសខាងមីសូរ, ព្រះសោណៈ និងព្រះឧត្តរៈ ទៅប្រកាសខាង ប្រទេសភូមានិងមន, នៅទីបំផុត ព្រះរាជបុត្រនិងព្រះរាជធីតារបស់ ព្រះបាទអសោក ត្រូវទទួលនាទីឲ្យចេញទៅប្រកាសសាសនាខាងកោះ លង្កា ។ បណ្ដាដែនដី ដែលព្រះបាទអសោក បញ្ជូនព្រះធម្មទូត ឲ្យចេញទៅប្រកាសព្រះសាសនានោះ មានអាណាចក្រខ្លះមិនបាននៅ

ក្រោមអំណាចរបស់ទ្រង់ទេ តែដោយអាស្រ័យ ទ្រង់ជាមហាអំណាចនៅក្នុងតំណៀងដូច្នេះ ទើបមិនមាននរណាហ៊ានទទឹងទាស់ឡើយ ។ មួយវិញទៀត ព្រះពុទ្ធសាសនាជាសាសនា ជួយសង្គ្រោះដោះទុក្ខរបស់មនុស្សលោកបានពិតៗ ទើបផែនដីទាំងឡាយ ក៏មានសត្វជ្រះថ្លាជាច្រើន ហើយគណៈធម្មទូតដែលចេញទៅប្រកាសសាសនាអស់នោះ ក៏បានធ្វើគុណប្រយោជន៍យ៉ាងសំខាន់ដល់ផែនដី ដែលខ្លួនបានប្រកាសផ្សាយព្រះពុទ្ធសាសនាប្ដូរដែនដេតកាន់ វេលានោះនៅជាព្រៃផ្សៃនៅឡើយ ក៏បានទទួលសេចក្ដីចំរើន រុងរឿងឡើងដោយអំណាចព្រះពុទ្ធសាសនា ហើយតំបន់ដែលសំខាន់បំផុត គឺ កោះលង្កានិងស្រុកតស្ទៈ ។

ព្រះមហិន្ទនិងព្រះនាងសង្ឃមិត្តា ជាព្រះឱរសនិងព្រះរាជធីតារបស់ព្រះបាទអសោកបានមកដល់កោះលង្កា បានដឹកនាំមហាក្សត្រកោះលង្កា ទ្រង់ព្រះនាមទេវានម្បិយតិស្សៈ ឲ្យមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ជាហេតុនាំឲ្យព្រះពុទ្ធសាសនាបត្តិស្ឋានក្នុងកោះលង្កាយ៉ាងមាំមួន កាលព្រះពុទ្ធសករាជ ៣១៣ ។ កាលដែលព្រះមហិន្ទនិងនាងសង្ឃមិត្តាថេរីនិមន្តទៅកោះលង្កានោះ បាននាំយកមែកពោធិព្រឹក្សដែលបានកាត់ចេញពីដើមដែលព្រះអង្គបានត្រាស់ដឹង ១ មែកទៅដាំនៅកោះលង្កា ហើយបានចំរើនឡើងរហូតមកដល់វេលានេះ ។

លុះព្រះពុទ្ធសាសនាចំរើនខ្លាំងខ្លួនក្នុងលង្កាទ្វីប ហើយពួកពុទ្ធសាសនិក-ជនលង្កាក៏ចេះសិក្សាព្រះវិន័យព្រះវៀនសូត្រ ទាំងគម្ពីរដីកា ហើយបានប្រកាសផ្សាយចេញទៅប្រទេសភូមា ថៃនិងឥណ្ឌូចិនទាំងអស់ផង ។ អំណើះកាលតមកដល់សម័យកណ្តាល ព្រះពុទ្ធសាសនា ត្រូវបណ្តេញចេញពីឥណ្ឌា ដោយការបៀតបៀននៃពួកសាសនាហិណ្ឌូនិងមហាម៉ាត ហើយកោះលង្កាក្លាយទៅជាកំពង់សំខាន់ ជាទីប្រជុំរបស់ព្រះពុទ្ធសាសនាផ្នែកខាងហីនយាន ។

ចំណែកខាងស្រុកខាងជើង គឺខាងកស្មីរៈនិងគន្ធារៈនោះ ព្រះសាវ័កជាអ្នកប្រកាសសាសនា បានធ្វើប្រយោជន៍មិនតិចជាងខាងស្រុកដទៃ ៗ ទេ ព្រោះព្រះមជ្ឈន្តិកៈ អ្នកនាំព្រះពុទ្ធសាសនាទៅប្រកាសផ្សាយក្នុងដែននេះ បាននាំព្រះភិក្ខុសង្ឃទៅផងចំនួនដល់ ៥០០ អង្គ លោកអស់នេះហើយ ដែលបានធ្វើឲ្យកើតសេចក្តីចំរើនខាងផ្លូវចរិយា និងសីល-ធម៌ដល់ប្រជាជននៅស្រុកអស់នោះ ហើយបានជួយពន្យល់បំភ្លឺ ដល់ប្រជាជនឲ្យបានចំរើនខាងរបរចិញ្ចឹមជីវិតរបស់មនុស្សដោយឡែកថែមទៀតផង ។ ស្រុកទាំងពីរនេះ ហើយដែលបានប្រកាសព្រះពុទ្ធសាសនាឲ្យផ្សាយចេញទៅស្រុកចិន និកាយមហាយានកើតឡើងក្នុងស្រុកទាំងពីរនេះដែរ ។

ទុកជាព្រះបាទអសោកទ្រង់បានទំនុកបំរុងព្រះពុទ្ធសាសនា ឲ្យបានបំរើនរុងរឿងដល់ម្ល៉ោះហើយក៏ដោយ ក៏នៅតែមិនទាន់សព្វព្រះរាជហឫទ័យ គឺទ្រង់នៅតែខំសង្វាតព្យាយាមផ្សាយព្រះពុទ្ធសាសនាចេញទៅទៀត រហូតដល់ដែនដែលពួកក្រិចកូលមកតាំងនៅ តាំងអំពីសម័យព្រះបាទអាលេក្សង់ដ្រ៍មហារាជ ហើយទ្រង់បានផ្សាយព្រះពុទ្ធសាសនាចេញទៅរហូតដល់ទ្វីបអឺរ៉ុបនិងទ្វីបអាហ្វ្រិចទៀតផង ។ មានសិលាចារឹកដែលទ្រង់ឲ្យចារឹកព្រះនាមរបស់ក្សត្រប្រទេសផ្សេង ៗ ដែលទ្រង់ជួយប្រកាសផ្សាយព្រះពុទ្ធសាសនា តែទ្រង់ឲ្យចារឹកព្រះនាមព្រះមហាក្សត្រអស់នោះជាភាសាបាលីទាំងអស់ ដូចជា អន្តិយក: (គឺព្រះបាទអន្តិអូគុសទី ២ ក្រុងស្រុកស៊ីរី) ១ តុរុមាយ: (ព្រះបាទប៉តូលេមេ ក្រុងកជ្យប្រទេសអ៊ីស៊ីប្ត) ១ អន្តិកេន: (ព្រះបាទអន្តិកូន ក្រុងស្រុកម៉ាសេដ្វាន) ១ អលិកសុន្ទរេ (ព្រះបាទអាលេក្សង់ដ្រ៍ ក្រុងស្រុកអេពិរុស) ១ និងស្តេចមក: (ស្តេចម៉ាគុស ក្រុងនគរតូចមួយ នៅទិសខាងកើតប្រទេសអេស៊ីប្ត) ១ ដោយហេតុនេះ ទើបត្រូវតែកត់ថាព្រះបាទអសោកបានប្រកាសផ្សាយព្រះពុទ្ធសាសនាបានធំទូលាយសំបើមអស្ចារ្យ មិនមានពុទ្ធសាសនិកជនណាមួយធ្វើបានដូចព្រះអង្គឡើយ ។ ក្នុងគ្រានេះយើងល្មមយល់បានថា ហេតុដូចម្តេច គោលធម៌គាថសំខាន់ ៗ ក្នុងគ្រិស្តសាសនាប្រហែលគ្នានឹងព្រះពុទ្ធសាសនាជាច្រើន ប្រសិនបើព្រះបាទអសោក

មិនទ្រង់ទំរើគតាប់ពេល ឬថាកាលទ្រង់ទំរើគហើយ មានមហាក្សត្រប្រតិបត្តិតាមស្នាមលំអានរបស់ព្រះអង្គដោយសទ្ធាជ្រះថ្លាមុតមាំ ហើយមានព្រះរាជសំណាងប្រពៃ ៗ ដូចព្រះបាទអសោកហើយ មិនបាច់សង្ស័យឡើយ អុំបតាំងពីបមុខជាបែរមុខមកកាន់ព្រះពុទ្ធសាសនាទាំងអស់ ហើយព្រះពុទ្ធសាសនាក៏ទៅជាទីគោរពគប់អាននៃលោកទាំងមូល ហើយសភាពរបស់លោក ទីងសភាពរបស់ស្រុកទេស ទីងខុសប្លែកពីសម័យសព្វថ្ងៃនេះជាច្រើន ៗ

កាលអស់បុណ្យព្រះបាទអសោកមហារាជហើយ ក៏មានមហា-ក្សត្រគ្រងរាជសម្បត្តិក្នុងដែនមគធៈត ៗ មកទៀត ៦ អង្គ តែមិនបានធ្វើឲ្យដែនមគធៈឲ្យចំរើនរុងរឿងឡើយ ទើបជាហេតុឲ្យព្រះបាទអន្ទិគុនសទី ៣ នៃប្រទេសស៊ីរីលើកទ័ពចូលលុកលុយប្រទេសឥណ្ឌា លុះដល់ក្នុងពុទ្ធសករាជ ៣៥៩ ក្សត្រមោរិយៈអង្គចុងក្រោយបង្អស់នោះត្រូវមេទ័ពរបស់ទ្រង់ធ្វើគតទៅ រាជវង្សមោរិយៈក៏ជាប់ចុងត្រឹមណោះឯង ៗ មេទ័ពដែលធ្វើគតទ្រង់នោះឈ្មោះ បុស្យមិត្រ តាំងខ្លួនឡើងជាក្សត្រគ្រងរាជ្យតាំងវង្សថ្មីហៅថារាជវង្សសុង្គៈ នៅក្នុងទីក្រុងបាដលីបុត្រដដែល តែព្រះរាជអំណាចថយតិចចុះទៅ ព្រះបាទបុស្យមិត្រទ្រង់កាន់សាសនាព្រាហ្មណ៍ ទើបជាសត្រូវនឹងព្រះពុទ្ធសាសនាយ៉ាងនៃក្រពេក បានដុតវិហារសាលាដែលព្រះបាទអសោកមហារាជ បានកសាងទុកមកនោះជា

ចំនួនច្រើន លុះមកដល់ពុទ្ធសករាជ ៣៨៨ ពួកក្រិកដែលនៅគ្រប់គ្រង ដែនបាកត្រៀន តាំងពីសម័យព្រះបាទអាលេក្សាន់ឌ្រ័មហារាជក៏លុកលុយចូលមក ព្រះបាទបុស្សយមិត្រនឹងក្សត្រវង្សសុង្គៈតៗមក ក៏បានព្យាយាមទប់ទល់រហូតដល់ឆ្នាំពុទ្ធសករាជ ៤៧១ ដរាបដល់ផុតរាជវង្សសុង្គៈ ហើយមានក្សត្រ ១ វង្សទៀតហៅថាវង្ស កណ្វា តែរាជវង្សនេះគ្រងរាជ្យបានត្រឹម ៤៥ ឆ្នាំ លុះដល់ពុទ្ធសករាជ ៥១៦ ក៏ផុតអំណាចអស់ទៅ ដែនមគធៈទាំងមូលក៏ធ្លាក់ទៅនៅក្រោមអំណាចក្រិក ។ ពន្លឺរស្មីនៃដែនមគធៈ ដែលធ្លាប់ថ្កុំថ្កើងរុងរឿងមក តាំងអំពីសម័យពុទ្ធកាលរហូតមកនោះ ក៏អស់ពន្លឺរស្មីក្នុងគ្រានេះឯង ។

ដើម្បីឲ្យយល់ប្រវត្តិសាស្ត្រឥណ្ឌា ក្នុងចំណែកនេះឲ្យបានច្បាស់លាស់ យើងត្រឡប់បែរទៅនិយាយអំពីអាណាខេត្រនៅទិសខាងជើង ដែលព្រះបាទអាលេក្សាន់ឌ្រ បានតាំងជាអាណាចក្រហើយនោះ ព្រោះនៅក្នុងប្រទេសនោះ មានមហាក្សត្រ ១ អង្គកើតឡើង ដែលជាក្សត្រដ៏សំខាន់ ១ អង្គក្នុងពង្សាវតាររបស់ព្រះពុទ្ធសាសនា គឺព្រះបាទមិលិន្ទ ។

(មានត)

3

# សម័យនគរភ្នំ

មហាស្រេម ទេពពិទូរ រៀបរៀង

(តមក)

## ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន

ព.ស. ១០១៣-១០៥៤, គ.ស. ៤៧០-៥១១.

ព្រះមហាក្សត្រិយ៍អង្គនេះ មានខ្សែព្រះលោហិតទាក់ទងដោយព្រាហ្មណ៍ ព្រះនាមដើម កោណ្ឌញ្ញ (ដូចរឿងកាលទី ១) ស្ដេចមកពីឥណ្ឌៀ ចូលមកកាន់នគរប៉ាមោ ចេញពីប៉ាមោចូលមកកាន់ស្រុកប៉ាន់ប៉ាន (កាន់ដែនមលយូ) ។ កាលព្រះបាទស្រីន្ទ្រវរ្ម័នទី ១ សោយទិវង្គតហើយ(១) រាជការនគរភ្នំ បានដំណឹងថា ស្ដេចមកដល់ស្រុកប៉ាន់ប៉ាន ក៏ត្រេកអរ ហើយចាត់ខុនឲ្យទៅទទួលអញ្ជើញស្ដេចមកគ្រងពិភពនគរភ្នំ មានព្រះបរមនាមថា «កោណ្ឌញ្ញជយវរ្ម័ន» ទ្រង់មានព្រះអគ្គមហេសីព្រះនាម សោមាទេវី ជាព្រះរាជបុត្រីក្សត្រិយ៍កាន់ព្រះរាជវង្សមុន, ក្រោយមកទ្រង់មានព្រះរាជទេវីទៀត ព្រះនាម ពាលាទិត្យ, មានព្រះរាជធីតាបន្ទាប់ ព្រះនាម សរស្វតី ។

---

១ ក្នុងពេលនោះ ប្រហែលជាគ្មានព្រះរាជវង្សដ៏សមគួរនឹងទទួលរាជសម្បត្តិ ។

ការផែនដី ៈ ក្នុងផ្លូវរដ្ឋប្រសាសនាផង ទ្រង់ឃើញកាលដែលទ្រង់បានតាក់តាំងកងទ័ពជើងគោក ជើងទឹក ព្រមទាំងរៀបរៀងក្បួនច្បាំង និងគ្រឿងសាស្ត្រាវុធយុទ្ធភណ្ឌ ទុកព្រមសម្រាប់ការពារប្រទេស , និងទ្រង់បានតែងកងទូតឲ្យនាំព្រះរាជសារទៅសុំចងសម្ពន្ធមិត្រនឹងស្ដេចប្រទេសចិន ។ កងទូតដែលទៅប្រទេសចិនក្នុងគ្រានោះ ជាព្រះថេរៈនាម សក្យនាគសេន ។ ព្រះមហាក្សត្រិយ៍ខ្មែរបានបញ្ជូនកងទូតទៅសុំចងសម្ពន្ធមិត្រនឹងស្ដេចចិនរាប់ជាគ្រាទី ៣ ក្នុងរជ្ជកាលនេះ ។

## សង្គ្រាមចាម្បគ្រាដំបូង

ព្រះសក្យនាគសេន ត្រឡប់មកអំពីប្រទេសចិន បានដំណើរកាត់នគរចម្ប៉ា, ស្ដេចចាម្បព្រះនាម ហៅតាមចិនថា (តាំងហោះជេ)[១] បានឲ្យទាហានចូលយករាជបណ្ណាការដែលស្ដេចចិនផ្ញើមកថ្វាយ ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នអស់ ហើយថែមទាំងប្រាប់ថា និងលើកទ័ពមកវាយប្រទេសខ្មែរទៀត ។ ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នកាលទ្រង់ជ្រាបពត៌មានតាមដែលព្រះសក្យនាគសេនថ្វាយព្រះពរហើយ ទ្រង់ព្រះចិន្ដាថា តាន់ហោះជេជាបុគ្គលពាលហួសប្រមាណ និងបណ្ដោយឲ្យបុគ្គលពាលមានអំណាចតទៅមិនជាការគួរសម ក្នុងករណីនេះជាមុខងាររបស់ព្រះអង្គ

---

១ ពង្សាវតារចិនថា តាន់ហោះជេ ជាតិជាខ្មែរតែជាខ្ញុំគេ រត់អំពីខ្មែរទៅនៅនគរចម្ប៉ា ក៏បំបះពួកចាមលើកទ័ពទៅសម្លាប់ស្ដេចចាមចង់ តាន់ហោះជេ ក៏បានឡើងសោយរាជ្យនៅចម្ប៉ា ។

ត្រូវតែចាត់ការក្រោមចៅ ទើបទ្រង់តែងរាជទូតឲ្យទៅសុំកងទ័ពចិនមកជួយបង្ក្រាប ។ ស្តេចចិនទ្រង់ជ្រាបសេចក្តីក្នុងព្រះរាជសារហើយ ក៏ត្រាស់ថាគាន់ហោនេមើលងាយព្រះបេស្កាព្រះអង្គ ទើបត្រាស់ឲ្យសេនាបតីរៀបចំទ័ពទៅវាយគាន់ហោនេ ដោយស្របតាមសេចក្តីសុំរបស់ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ។ គ្រានោះ កងទ័ពចិនលើកមកវាយចម្ប៉ាផ្លូវពីខាងជើង, កងទ័ពខ្មែរលើកទៅវាយផ្លូវពីខាងត្បូង ដោយព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នទ្រង់តំណែងជាក្សត្រិយ៍សឹកបញ្ចប្រាំងដោយព្រះអង្គឯង ។ គាន់ហោនេក៏បរពលចេញច្បាំងតទល់ពេញទំហឹង តែទប់កំឡាំងកងទ័ពខ្មែរនឹងចិនពុំបាន ក៏បរាជ័យទៅក្នុងរយៈវេលាមិនយូរប៉ុន្មាន គាន់ហោនេក៏ត្រូវប្រហារជីវិតបង់ក្នុងទីរៀនវង្គ ។ ព្រះបាទកោណ្ឌញ្ញ-ជ័យវរ្ម័នទ្រង់តាំងព្រះរាជវង្សខ្មែរ ១ ឲ្យជាចៅបរជនៅត្រួតត្រាខេត្តចម្ប៉ាក្នុងឋានៈជាប្រទេសរាជ, ចម្ប៉ាបានធ្លាក់មកនៅក្រោមឥទ្ធិពលខ្មែរក្នុងគ្រានោះ (ព.ស.១៥៨៧) ជាដំបូង ។ កាលស្រេចព្រះរាជសង្គ្រាមហើយ ទ្រង់ជប់លៀងទាហានចិននិងព្រះរាជទានរង្វាន់តាមសមគួរហើយ ក៏បញ្ជូនត្រឡប់មកស្រុកចិនវិញ ។ ចំណែកព្រះអង្គក៏ស្តេចលើកទ័ពត្រឡប់មកព្រះនគរ ។

សង្គ្រាមគ្រានោះ ធ្វើឲ្យព្រះមហាក្សត្រិយ៍ចិនឃើញឥទ្ធិពលព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នដែលទ្រង់ជាវីរៈក្សត្រិយ៍នឹងថ្នាក់ក្នុងវិជ័គលយុទ្ធ

ដឹងគេនោះ ទើបទ្រង់តាំងក្នុងតំណែងជាមេទ័ព ដ៏មានកិត្តិយសខ្ពស់ ហៅថា «មហាក្សត្រិយ៍សឹកក្នុងប្រទេសប៉ែកខាងត្បូង» ។ ក្នុងបណ្តាព្រះមហាក្សត្រិយ៍ទាំងឡាយរបស់ខ្មែរ ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ទ្រង់បានទទួលព្រះកិត្តិយសជាមហាក្សត្រិយ៍សឹក ប្រាកដនៅក្នុងប្រវត្តិសាស្ត្រ ជាអង្គដំបូង ។

ក្រោយនោះ ទ្រង់បានលើកកងទ័ពទៅគ្រាបប្រទេសប៉ែកខាងលិច និងប៉ែកខាងជើង ។ ប៉ែកខាងលិចទ្រង់វាយយកបានប្រទេសមនទាំងមូល ដល់ទៅទន្លេឥរាវតី ។ ប៉ែកខាងជើងទ្រង់វាយយកបាននគររបស់លាវ និងវាយរុកទៅលើទៀត ដល់នគរភុំគង ។ ក្នុងពង្សាវតារភូមា (១) ថាមនុស្សជាតិដែលគ្រប់គ្រងដែនមន មុនដែលភូមាផ្លាយពីទីបេតមក គឺជាតិខ្មែរ មានអំណាចធំក្រៃលែង គ្របគ្រងដែនសុវណ្ណភូមិ មានព្រំប្រទល់អាណាខែត្រ (ការខាងនេះ) តាំងពីទន្លេឥរាវតី ឡើងហូរទៅដល់នគរភុំគងខាងលើ ប៉ុន្តែមិនឆ្ងាយជាងនេះ ក៏ដល់ខែត្រអស្សមក្នុងបច្ចុប្បន្ន» ។

តាមប្រវត្តិសាស្ត្រដ៏មានមក យើងកាត់កំណត់ដែនទីព្រំប្រទល់ព្រះរាជអាណាចក្រក្នុងរជ្ជកាលនេះបាន គឺ

---

១ ច្បាប់ដែលក្រុមព្រះនរាធិបប្រពន្ធពង្ស ទ្រង់ប្រែជាភាសាសៀម ។

ខាងកើត ផុតដែនចម្ប៉ា

ខាងលិច ផុតដែនមន

ខាងត្បូងទល់សមុទ្រ

ខាងនិរតី ដល់ពាក់កណ្តាលដែនទាលយូ

ខាងជើង ដល់នគរគុនមិង ។

តាមផ្ទៃទីនេះ ឃើញថា ព្រះរាជអាណាចក្រខ្មែរក្នុងសម័យនគរភ្នំ ធំជាងក្នុងសម័យណាៗ ទាំងអស់ ។

## ប្រវេណីគ្រប់គ្រងផ្ទៃក្រោម

វិធីគ្រប់គ្រងផ្ទៃក្រោមរបស់ខ្មែរក្នុងសម័យនគរភ្នំនោះឃើញថា ផ្ទៃ យកបែបគ្រប់គ្រងយ៉ាងឥណ្ឌាមកប្រើ ស្ទើរតែគ្រប់យ៉ាងដូចតទៅនេះ ។

ក្នុងសម័យដែលព្រះមហាក្សត្រិយ៍មានអំណាចពាសស័ក្តិធំមានព្រះរាជអាណាចក្រធំទូលាយ, ព្រះរាជអាណាចក្រទាំងមូលនោះ រមែងត្រូវបែងជា ២ សង្កាត់ គឺស្រុកទាំងឡាយដែលតាំងនៅក្នុងសង្កាត់ខាងក្នុង ឬសង្កាត់កណ្តាល ហៅថា មជ្ឈមរដ្ឋ (=ដែនកណ្តាល) សង្កាត់នេះ នៅក្នុងអំណាចគ្រប់គ្រងរបស់ព្រះមហាក្សត្រិយ៍ រាជាធិរាជ ។ ស្រុកធំៗ ដែលតាំងនៅតាមជាយដែន ក្រៅអំពីមជ្ឈមរដ្ឋចេញទៅសឹងធ្លាយ ដាច់ស្រយាលអំពីព្រះរាជធានីធំ មិនមានកំណត់ចំនួនទាត់ជារដ្ឋមួយ ៗ ហៅថា បច្ចន្តរដ្ឋ (=រដ្ឋជាយដែន) ។ បច្ចន្តរដ្ឋនេះ មានការគ្រប់គ្រង

ដាច់ដោយឡែក ដោយព្រះរាជាធិរាជទ្រង់តែងតាំងព្រះរាជវង្សដែលមានសមត្ថភាពនិងជាទីទុកព្រះរាជហឫទ័យឲ្យទៅនៅគ្រប់គ្រង ទ្រង់ព្រះរាជទានអំណាចឲ្យបញ្ញត្តច្បាប់សម្រាប់ប្រើក្នុងរដ្ឋនោះ ៗ ឲ្យមានអំណាចតែងតាំងមន្ត្រីរាជសេនាបតីជាដើម និងតាំងក្រសួងការទាំងពួងដោយខ្លួនឯង តែក្នុង ១ ឆ្នាំ គឺក្នុងឱកាសចូលឆ្នាំកល់ ៗ ឆ្នាំត្រូវនាំផ្កាមាសផ្កាប្រាក់ និងសួយសារអាករ ដ៏ជាផលរបរ ក្នុងស្រុកនោះ ៗ មកថ្វាយព្រះមហាក្សត្រិយ៍រាជាធិរាជ ។

ស្រុកដែលធ្លាប់តាំងជាបច្ចន្តរដ្ឋ មានព្រះឧបរាជគ្រប់គ្រងក្នុងសម័យនគរភ្នំ ឬរហូតដល់សម័យនគរធំ គឺរដ្ឋស្រេឋម្មនគរ ( នគរស្រេឋម្មរាជ) ក្នុងដែនលាវ ក្នុងបច្ចុប្បន្ននេះជារបស់សៀម តាំងរាជធានីនៅស្រេឋម្មនគរ ។ រដ្ឋទ្វារវតី តាំងរាជធានីនៅអយុធ្យា តែដូនកាលលើកទៅតាំងនៅលវោ (លពបុរី) ។ រដ្ឋគោត្របុរៈ តាំងរាជធានីនៅភិម៉ាយ ។ រដ្ឋនគរភ្នំ តាំងរាជធានីនៅនគរភ្នំនៅខាងលិចជាខែត្រសព្វថ្ងៃ ភូមិភាគខាងលើ គឺពីនគរភ្នំទៅទល់នគរគូកិន គង់មានតាំងជារដ្ឋសម្រាប់ព្រះឧបរាជ ១ អង្គទៀត តែមិនដឹងជាតាំងរាជធានីនៅទីណាជាប្រាកដ ដោយសន្និដ្ឋានថា ប្រហែលជាតាំងនៅវៀងចន្ទ និងហ្លួងព្រះបាង ។ នៅមណ្ឌលកូសាំងស៊ីនក៏ធ្លាប់មានព្រះឧបរាជគ្រប់គ្រង ១ អង្គដែរ តាំងរាជធានីនៅឃ្លាំង ដូនកាលតាំងរាជធានីនៅទីដទៃទៀតក៏មាន ។

ចំណែកប្រទេសណាគ្រប់គ្រងប្រទេសឯករាជដែលជារបស់ជាតិដទៃ តែត្រូវធ្លាក់មកនៅក្រោមឥទ្ធិពលខ្មែរ បើមិនត្រូវការដាក់ប្រទេសនោះបញ្ចូលមកក្នុងព្រះរាជាណាចក្រទេ ត្រូវទុកប្រទេសនោះជាប្រទេសឯករាជ ត្រូវតាំងក្សត្រិយ៍ក្នុងប្រទេសនោះឲ្យគ្រប់គ្រងខ្លួនឯង តែត្រូវនាំកដប្បណ្ណាការមកថ្វាយព្រះរាជាធិរាជរៀងរាល់ឆ្នាំ ដូចព្រះឧបរាជដែលគ្រប់គ្រងបច្ចន្តរដ្ឋ ។

ក្រៅអំពីការពង្រីកព្រះរាជាណាចក្រ ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ទ្រង់បានបំពេញព្រះរាជករណីយកិច្ចទំនុកបំរុងប្រជារាស្ត្រ តាមឋានៈព្រះអង្គជាមហាក្សត្រិយ៍ម្ចាស់ផែនដី គឺការឧស្សាហកម្ម ទ្រង់ទំនុកបំរុងរាស្ត្រឲ្យសិក្សាវិជ្ជាជំនាញផ្សេងៗ មានការត្បាញសំពត់ជាដើមឲ្យល្អលើសក្នុងកាលមុនៗមក ទីនទ្រង់រៀបចំការតែងកាយឲ្យមានរបៀបថ្លៃថ្នូរឡើង, ការសេដ្ឋកិច្ច ទ្រង់ឲ្យជីកស្រះ ជីកគូ ធ្វើទំនប់ទឹកដីជាប្រយោជន៍ក្នុងការប្រើប្រាស់ទឹកក្នុងការធ្វើរបរសេដ្ឋកិច្ច, ការវេជ្ជកម្ម ទ្រង់ទំនុកបំរុងវិជ្ជាពេទ្យ ទីនតាំងអគារពេទ្យសាលាឲ្យនៅពេញទូទៅក្នុងព្រះរាជាណាចក្រ ។

ការព្រះសាសនា = ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ទ្រង់គោរពរាប់អានទាំងសាសនាព្រាហ្មណ៍ ទាំងព្រះពុទ្ធសាសនា, ទីនទំនុកបំរុងសាសនាទាំងពីរនេះ ភស្តុតាងក្នុងរឿងនេះ គេប្រទះឃើញសិលាចារឹក

២ អន្ទើ គឺសិលាចារឹក ១ សំដែងសេចក្តីលើកដល់ព្រះវិស្ណុ សិលាចារឹក នេះនៅជាប់មួយ តំបន់លកក់ ក្នុងដែនកូសាំងស៊ីន ៗ សិលាចារឹក ១ ទៀត រំលឹកដល់ព្រះពុទ្ធ គេឃើញនៅស្រុកបាទី (ខេត្តតាកែវ ចារឹកទាំងពីរនេះគេសាងឡើងក្នុងរវាង ព.ស. ១០៤០ ដល់ ១០៥០ សឲ្យឃើញថា ក្នុងសម័យនោះ សាសនាទាំងពីរបានមកប្រតិស្ឋាន ក្នុងប្រទេសខ្មែរយ៉ាងចំរើនហើយ តែខាងសាសនាព្រាហ្មណ៍នោះ គេនិយមគោរព ព្រះហរិហរៈ ខ្ពស់ជាងយ៉ាងដទៃ ដោយមានរូបភាព ព្រះហរិហរៈ ច្រើនជាងរូបភាពយ៉ាងដទៃ នៅដល់សព្វថ្ងៃនេះ ៗ ឯព្រះពុទ្ធសាសនាក្នុងសម័យនោះ មានទាំងលទ្ធិស្ថវិរៈ (ហីនយាន) ទាំងលទ្ធិអាចារ្យវាទ (មហាយាន) ព្រះបាទកោណ្ឌញ្ញជយវរ្ម័ន ទ្រង់និយមក្នុងព្រះពុទ្ធសាសនាលទ្ធិស្ថវិរៈ ជាងលទ្ធិដទៃ, ប្រាកដក្នុងពង្សាវតារចិនថា ក្នុងប្រទេសរបស់ព្រះបាទ កោណ្ឌញ្ញជយវរ្ម័ន មានអាចារ្យក្នុងព្រះពុទ្ធ-សាសនាច្រើនដេរដាស ៗ ក្នុងលទ្ធិស្ថវិរៈនិងអាចារ្យវាទនោះ គេសង្កេតឃើញលទ្ធិស្ថវិរៈ រុងរឿងជាង ដោយហេតុអ្នកស្រុកបានទទួលសិក្សា និងជ្រះថ្លា ក្នុងធម្មព្រះត្រៃបិដករបស់ខាងលទ្ធិស្ថវិរៈ ដែលបានចំលងមក ពីលង្កាក្នុងរជ្ជកាលព្រះបាទចន្ទនៈ, ទាំងក្នុងវេលានោះមានព្រះមហាថេរ ២ អង្គ គឺព្រះសក្យមាគសេន មកអំពីឥណ្ឌា ១ ព្រះសង្ឃបាល ១

តាំងពីគ្រានេះជាអ្នកថែទាំទុកព្រះត្រៃបិដកយ៉ាងបរិបូណ៌, ព្រះសង្ឃបាល ប្រែហៅថាមានតំណែងជាសង្ឃនាយក: ព្រះពុទ្ធសាសនាបានរុងរឿងឡើងក្នុងវេលានោះ ដោយអំណាច ព្រះមហាថេរទាំង ២ អង្គនេះផងដោយអំណាចព្រះមហាក្សត្រិយ៍ទ្រង់ទំនុកបម្រុង ។

ក្នុងគ្រាបង្កើតសម្ពន្ធមិត្រនឹងប្រទេសចិន ព្រះបាទកោណ្ឌញ្ញជយវរ្ម័នទ្រង់អារាធនាព្រះសក្យនាគសេនឲ្យជារាជទូតទៅប្រទេសចិន, ក្រោយពីនោះមក ២០ ឆ្នាំ ព.ស. ១០៤៦ ស្តេចចិនឲ្យរាជទូតនាំព្រះរាជបណ្ណាការមកសុំព្រះសង្ឃគណៈស្ថវិរៈទៅផ្សាយនៅប្រទេសចិន ។ ព្រះបាទកោណ្ឌញ្ញជយវរ្ម័នទ្រង់អារាធនាព្រះសង្ឃបាលឲ្យទៅ ប្រែជាបរិយត្តិធម៌នៅក្រុងចិន អស់វេលា ៤ ឆ្នាំ ទើបត្រឡប់មកវិញ ។ ក្នុងរឿងនេះរាប់ថាជាកិត្តិយស ១ យ៉ាងរបស់ខ្មែរយើង ។

ការក្នុងរាជត្រកូល, ព្រះបាទកោណ្ឌញ្ញជយវរ្ម័នទ្រង់តែងតាំងព្រះពាលាទិត្យឲ្យទៅគ្រងអធិក្ខុតបុរៈ (នៅកោះកែខាងលិចព្រហ្មទេត) ទ្រង់ព្រះរាជទានព្រះនាងសរស្វតី ឲ្យជាភរិយាព្រាហ្មណ៍ប្រាជ្ញឈ្មោះវិស្វរូប ។ ព្រះរាជវង្សកោណ្ឌញ្ញបានតំណរាជសន្តតិវង្សនឹងផ្សាយចេញទៅជួបេះ :

(មានត)

# លោកវ៉ាយ-ប៊ុក រៀបរៀង

(តមក)

## ២ បណ្ឌិតវគ្គ

១ - ទ្រព្យធនកើតក្រោយកិរិយា បើរកកិរិយាវើសមារយាទ ក្រៃទ្រព្យមាសប្រាក់បញ្ញាផ្តាត ហៅមានតាមខ្លួនគង់ពក់ខ្លួន ។

២ - មនុស្សម្នាក់មានគេស្អប់ស្រឡាញ់ ពាលអាចកាប់ចាញ់ ចាក់សម្លាប់ បណ្ឌិតអាចក្តីសុចរិតគាប់ ពារគេតសត្រូវអាចតៃយ៉ ។

៣ ធម្មជាតមនុស្ស សុចរិតល្អស្មោះ មិនបានមួយជាតិ មាន ខុសត្រូវខ្វះ ប្រព្រឹត្តជាអាទ៍ បំពេញខ្វះខាត ធម្មតាលោកិយ ។

៤ - វត្ថុក្នុងលោក មនុស្សសត្វទ្រព្យគោត អប់រំនិស្ស័យ បង្ហាត់ បង្រៀន តាក់តែងសម័យ គង់មានជំនឿ ក្នុងប្រជុំជន ៗ មាសពេជ្រ បរិណ ដុសខាត់កាត់ច្នៃ ត្បូងឲ្យគយគន់ រុក្ខជាតិកាត់មែក ពត់ពេន ល្អលន់ បត់បែនតាមជន ជាតិយើងនិយម ។

៥ - អ្នកកាន់សច្ចៈ ត្រូវតប្បត្ត អ្នកក្លាហានពិតស្ដេចត្រូវការ អ្នក បេះដូងសប្បុរសពេញ អ្នកមានពោធិតែងរាប់អាន ។

៦ - ជាង៏អ្នីមិនស្មើជាងសង្ការ អ្នកប្រាជ្ញធម៌អាចមិនស្មើពុទ្ធ សការៈមិនស្មើធម៌បរិសុទ្ធ អ៊ីមុតមិនស្មើចិត្តមុត ។

៧- រៀនលោករៀនធម៌ រៀនជាតិយល់ក្រ រៀនសាសនាកត រៀនច្បាប់មាត្រា រៀនវិជ្ជាគ្រប់ រៀនថ្ងៃរៀនយប់ រៀនហើយរៀនទៀត ។

៨- អរហត្តផលឈ្នះកិលេស ប្រាជ្ញបេះយូរទៅឈ្នះពួកល្ងង់ សន្តិភាពយូរឈ្នះសង្គ្រាមផង ធម៌ល្អឥតហ្មងឈ្នះអាក្រក់ ។

៩- ស្រមោលលើដីប្តូរផញ្ចាំង មានរឿងយន្តតាំងស្រូបយកបាន ទុកស្នាមគំនូសយល់រូបរាង ស្គាល់ភាពតាមរាងវៃបងម្ជាតិ ។

១០- ថ្ងៃមាសគេគោះស្គាល់ទុំខ្ចី ជាតិមនុស្សប្រុសស្រីគ្រាសោគ ស្មូរ លលួកបាញ់ពាញពោលគាប់ខួរ ទើបឃើញខួរក្បាលល្អអាក្រក់ ។

១១- ឆ្នាំងពាងមានស្រែចងបមានធ្រូត មាត់ភាពទំនុកមានគន្លឹះ ទូមានបង្កិតពស់មានពិស កូនសិស្សល្អមានគ្រូប្រៀនប្រដៅ ។

១២- វិជ្ជាមិនចេះចេះតែទ្រា ព្រួយព្រាណអាត្មាការល្ងង់ខ្លៅ កើតចេតមិនស្គាល់កេសដ្ឋះទៅ បង់គ្រប់តាមផ្លូវមិនស្គាល់ច្រក ។

១៣- កុំយោសដើងហួស ខ្លួនតូចប៉ុនក្រួស ប្រណាំងភាពធំមើល ហួសមាត្រា ផែងខុសក្រមក្រិត្យ ខ្លួនជាតិហ៊ឹងពិត បង់ប៉ោងប៉ុនគោ ។

១៤- ស្វាបន៍ពាក់ម្កុដ លាក្រាប់ថ្កួត ក្អកទឹកក្រាប់គោក ល្ងង់ក្រាប់បណ្ឌិត កស្រួតាមប្រយោគ ក្រាប់ស្តេចឥតជោគ មិនសមឋានា ។

១៥ — ខ្លួនខ្សោយបង់ធុរលោកមេឃា កុំភ្លេចតស៊ូការកំណើតមនុស្ស ខ្លួនជាខ្មែរស្រឡាញ់ជាតិស្មោះ បង់ខ្សែលើផ្លូវបោះជំណើរទោល ។

១៦ — មនុស្សច្រើនគាប ការងារប្រែសាប ផ្លូវបត់ល្បិចការ តំរួនច្រើនក្រុម ជាតិច្រើនភាសា ចិត្តច្រើនប្រការ និញ្ញាណតែមួយ ។

១៧ — ចង់ដឹងការមនុស្សដោយសេពគប់ ចង់ដឹងគុណគេ ដោយមិត្តសុខា ដឹងពាលបណ្ឌិតដោយបរោត ចង់ដឹងតាក្ដាត្រូវអប់រំ ។

១៨ — ឈ្នះប្រទេសដោយតែនិពួល្យ ឈ្នះស្បៀងប្រយោជន៍ពិសេស ឯក ឈ្នះខ្លួនឯងឧត្ដមថ្លៃ ហៅឈ្នះចំឡែកលែងបាញ់វិញ ។

១៩ — កុំឲ្យគ្រូញញែរ ខាំកុំគិតថ្លៃ កុំសោះអសោភា កុំបន់ព្រះ ព្រហ្ម ឲ្យបើកនេត្រា គិតគូរធ្វើការ ត្រាតែដល់ត្រើយ ។

២០ — កុំត្រាប់សត្វ បៀនកូនពីក្បាលព្រៃ ប្រមាថក្លួចស្លាប់ ឲ្យត្រាប់បង្រិក ធ្វើខ្លួនប្រុងស្រាប់ ហេក់ខ្លួនពួនផ្ដាប់ មិនប្រួសភាគ្នា ។

២១ — ការឈ្លោះគាស់ថែនស្ដេចមន្ត្រី ជាហេតុបច្ច័យវិនាស ជាតិ ខេមរាត្រូវគ្នាកៃប្រមាថយាង ទ័ព្យាពច្រើនតែគំនិតចិត្ត ។

២២ — ជីងចក់ផ្លាស់ពណ៌តាមកន្លែង ពួកជនពាលតែងផ្លាស់មារយាទ ដោយការប្លន់ផិតបណ្ឌិតជាតិ គន់ប្រែបទបាទលាល់ខុសត្រូវ ។

២៣ — កុំបោះត្រីរមៀតតែនឹងផ្កាស់ពណ៌ ខ្សែហាក់ស្តាប់ធម៌លោភ ទេសនា បួលជិតនារីប្រែសរគនា ត្រាប់ក្បួនកមកប្រាជ្ញាឈ្លាស ។

២៤ – កុំត្រាប់មេអំបៅហើរត្រេច មិនបានសម្រេចកិច្ចត្រង់ណា ត្រូវត្រាប់សត្វឃ្មុំត្រេចបុប្ផា មកធ្វើនែហាសំបុកនៅ ។

២៥ – កុំត្រាប់ពុកដែលជាប់មានស្លាម ឲ្យប្រែព្រឹត្តតាមក្រមួនឃ្មុំ ពាលត្រូវក្តៅក្លាយជាទឹកទុំ ដល់ត្រជាក់ដុំជាក្រមួន ។

២៦ – ស្តេចចូលស្រុកភូមិមិនដែលស្គាល់ បុគ្គលខ្លាត់ខ្លាត់កុំទៅបៀត ត្រូវស្គាល់ដំណើរបុគ្គលារយាទ បេញខ្លាតប្រាជ្ញឈ្លាសឬល្ងង់ខ្លៅ ។

២៧ – ចង់ធំឲ្យគួរ ចង់ខ្ពស់ទាបពួជ ចង់បានឲ្យបង់ ចង់ចេះឲ្យរៀន ចង់ជឿឲ្យត្រង់ ចង់ស្រួលឲ្យស្រង់ ខ្នងពីលំបាក ។

២៨ – ប្រយ័ត្នកាចា តោះប្រើប្រាជ្ញា យល់ពាលបណ្ឌិត កិច្ចពលកន្លែងក្រៅ ក្លើនផ្សេងពិនិត្យ ស៊ើបឈើដោយដៀត ឆក្រែកខ្យល់បក់ ។

២៩ – ខំរៀនឲ្យចេះ ប្រាជ្ញាឲ្យត្រេះ ខ្សែនាយល់បង្ហាស់ ប្រឹងដើរទើបដល់ ធ្វើឲ្យស្រឡាស់ គិតឃើញយល់ច្បាស់ ដំណើរលោកិយ ។

## ប្រជុំពាក្យព្រេងចិនជាភាសាបារាំង

## លោកវ៉ាយ-ប៊ុក រៀបរៀង

(តមក)

18 — Endurer pour durer

១៨ — អត់ធន់ដោយខន្តី ដើម្បីធ្វើការលទ្ធបាន

ខន្តីកំណត់ ជាធម៌កំណត់ នៃក្រៃក្រែងជាមហា ទម្លាប់ការយារជពា្យបា

ទោសា ត្រូវកាត់បន្ថាដោយសារតោលបាន ។

19 — A chaque jour sa peine

១៩ — គ្រប់ថ្ងៃមួយ ៗ ត្រូវតែនឿយហត់

ត្រូវតែធ្វើការគោរ នេះជាច្បាប់សម្រាប់ប្រាណ ប្រុសស្រីតាម

លំនាន នឿយហត់ប្រាណបានក្តីសុខ ។

20 — Sans pitié pour les parjures

២០ — មនុស្សហ៊ានស្បថបំពាន មិនត្រូវត្រាប្រណី

អ្នកស្បថបំពាន គំនិតគតខ្មាន ត្រូវក្រែងសុចរិត ហ៊ានពុះបំពារ

បំពានលោកិក ខ្វះគុណគិត ត្រាប្រណីឡើយ ។

21 — Pourquoi pas ?

ហេតុអ្វី ក៏ជាទេ ?

កិច្ចដែលធ្វើកើតខ្លួនព្យាយាម ធ្វើតាមលំនាននិងបានការ កុំនិងថា

«ទេ» ណា ត្រូវប្រឹងសង្រាប់ក្រាផលត្រៃយ ។

22 — A cœur vaillant, rien d'impossible.

២២ — បើចិត្តក្លាហាន ធ្វើការអ្វីក៏កើត

បើចិត្តក្លាហាន ធ្វើការលំបាក ធ្ងន់ប៉ុណ្ណា ចិត្តតស៊ូមាំ ទំប្រឹងធ្វើការ ព្យាយាមស្វះស្វាក់ ក៏តែដល់ត្រើយ ។

23 — Moi seul et c'est assez.

២៣ — តែខ្ញុំម្នាក់ឯងប៉ុណ្ណោះល្មមហើយ ។

«គួរគិតខ្លួនមួយ តែងមានទុក្ខព្រួយ ផងញាតិសន្តាន សាច់សាលោហិត ទីងមិត្តកល្យាណ ត្រូវតែឲ្យមាន ញាតិមិត្តសព្វគ្រប់» ។

24 — Contentement passe richesse

២៤ — សប្បាយចិត្តប្រសើរជាងមានសម្បត្តិ

«ចិត្តថ្មើរតែកាយ ទ្រព្យផងសម្បាយ សេដ្ឋីមិនដល់ ធុះចុះសំណា គិតព្រួយសល់វល់ កើតទុក្ខធ្ងន់ សប្បាយពីអ្វី» ។

25— A confiance, bonne chance

២៥ - ទុកចិត្ត ជាជោគល្អ

«ធ្វើការនានាទុកចិត្ត បណ្ដាំតពោលថាមិនស្រួល ធ្វើការទុកចិត្តថ្កុត មិនយល់គិតមិនកើតការ» ។

26 — Une foi, une loi, un roi

២៦ — ជំនឿ ១ បញ្ញត្តិ ១ ក្សត្រិយ៍ ១

« ជំនឿបញ្ញត្តិនឹងមហាក្សត្រ ទាំងបីមាំគុណជាំងជ័យ ជាទីគោរពមានជំនឿ នាំជាតិថ្កុំថ្កើងហានផស្សារ» ។

27 — Tout par amour, rien par force —

២៧ — ប្រើមេត្តាបានផលជាងប្រើកំឡាំង ។

« បើមេត្តាចិត្តបានផលច្រើន ត្រាំត្រកើនដោយផ្សំ។ បាយ ប្រើកាចហិនហៃមិនមែនល្អ ត្រូវយល់ខ្ទមស្រាយរបស់មនុស្ស » ។

28 — Toujour prêt —

២៨ — ត្រូវប្រុងខ្លួនជានិច្ច -

« លោកមានគ្រោះថ្នាក់ច្រើន ត្រូវក្រើនរាំងខ្លួន កម្មផលលាក់បំពួន ត្រូវថែជួនកុំប្រមាទ ។

29 — Plutôt rompre que ployer —

២៩ — ស៊ូឲ្យបាក់ទៅ កុំឲ្យងក្ក -

« កុំឲ្យគេពក់មួលការមារ ត្រូវប្រយុទ្ធតាពល់បាញ់ឈ្នះ មិនឲ្យមើលងាយជាតិកូនប្រុស បើស៊ុះសន្ធឹងឲ្យដល់បាក » ។

30 — Ni crainte, ni envie —

៣០ — កុំខ្លាច កុំឥច្ឆា -

« ខ្លាចនាំខូចការ នាំជាតិសាសនា កាន់ហិនហោះតាប មិនត្រូវឥច្ឆា ឈ្នានីះដល់លោក ព្រេងណាមបានបាប ខូចបុណ្យសោរ » ។

31 — Dieu y pourvoira —

៣១ — ព្រះទ្រង់ចំនុតកក់ក្រុមមនុស្សលោក -

« បើខ្ញាក់គប្ជន់ព្រះបញ្ញើម ខ្ញាក់សើបញញឹមប្រែងបានប្រាក់ គប្ជន់ធ្វើការតាមចិត្តស្រែ ខ្ញុំមានដៃធ្លាន់ធ្វើជាជាង » ។

32 — Je meurs où je m'attache —

៣២ — ខ្ញុំស្លាប់នៅកន្លែងណា ដែលខ្ញុំពេញចិត្ត-

« ស្លាប់ក្រោមទង់ជាតិ ការពារសាច់ញាតិ មាតុភូមិកាក្តា ជាស្លាប់ប្រសើរ ជាងស្លាប់ជម្ងឺ ខ្លួនមុខមេឃា ឈរចេញរកជា» ។

33 — Vertu me guide, honneur me conduit —

៣៣ — គុណធម៌នាំផ្លូវខ្ញុំ កិត្តិយសដឹកនាំខ្ញុំ

«គុណធម៌ដឹកនាំវិសេសពិត កិត្តិយសត្រូវតែគិតតាមបុណ្យបាប ស្រេចនៅប្រព្រឹត្តទំព្រះសាប បានផលខ្ពស់ទាបតាមបរិយោ» ។

34 — Qui s'y frotte s'y pique —

៣៤ - អ្នកណាហ៊ានត្រដុសខ្លួននឹងបន្លាមុខជាមុតបន្លា -

« មានទុក្ខព្រោះថ្នាក់ត្រូវប្រាណ ជិតតាមលំអានរូបសង្ខារ តែងត្រូវទុក្ខស្ទុះជាធម្មតា កម្រផងណាចៀសវាងរួច» ។

35 — En tout lieu et à toute heure·

៣៥ - នៅគ្រប់ទីកន្លែង នៅគ្រប់ពេលម៉ោង ៗ កុំប្រមាទគ្នា គ្រប់ពេលវេលា ម៉ោងយាមខាង ពិនិត្យគ្រប់ថ្នាក់ ខ្ពស់ទាបវែងខ្លី សព្វគ្រប់កុំបី ចង់ពេលគសារ» ។

( មានត )

# រឿងធ្វើស្រែខ្មែរនៅកម្ពុជាក្រោម

(គូស័ងស៊ុន)

លោកអាចារ្យ ឌិញ - ប្រាជ ហៀបហៀង

(តមក – ចប់)

---

## អំពីការធ្វើលាន

បើពូនចណ្ដាប់រួចហើយត្រូវរៀបចំធ្វើលានសម្រាប់បោកស្រូវតទៅ លាននោះធ្វើក្នុងស្រែណាដែលគេគប្បីធ្វើក្នុងភូមិក៏បាន តែគេច្រើនធ្វើកន្លែងដែលស្រឡះប្រយោជន៍ដល់ពេលបោកបានខ្យល់ងាយរោយ ។

បើធ្វើលានក្នុងស្រែ ដំបូងត្រូវចាំងគល់ចញ្ចាំងប្រមូលយកចេញឲ្យអស់ ហើយយកក្របីឬគោបញ្ចាន់ដីនោះឲ្យហាប់ល្អហើយយកកបបចាំងស្នាមជើងក្របីគោនេះឲ្យស្មើ ហើយដងទឹកមកស្រោចឲ្យជោគ ហើយយកជើងកៀរឲ្យរលីងស្អាតមែនទែន ។

បើធ្វើក្នុងភូមិត្រាន់តែចាំងស្មៅឲ្យស្អាតហើយបោសឲ្យរលីងប៉ុណ្ណោះបានហើយ ព្រោះដីក្នុងភូមិហាប់ស្រាប់មិនបាច់ចាំបញ្ចាន់ទៀតទេ ប៉ុន្តែលានទាំងពីរនេះបើធ្វើសព្វគ្រប់ដូចគ្នាហើយ ត្រូវយកចំបើងមកក្រាលពីលើឲ្យស្ដើង ៗ ប្រយោជន៍កុំឲ្យដីបែកក្រហែងក្រែងគ្រាប់ស្រូវហូរចូលតាមក្រហែងដីនោះ បើធ្វើលានរួចហើយត្រូវរៀបចំដឹកស្រូវតទៅទៀត ។

# អំពីការដឹកស្រូវ

បើស្រែនៅមានទឹកត្រជឹកជោយគាត់ គឺយកក្របីឬគោមកទឹម ហើយយកជំរៀវដាក់លើគាំ យកខ្សែ ១ ចងពីក្តាក្រោមគាំទៅក្បាលជំ-រៀវទាំងសងខាង ខ្សែនេះហៅថាខ្សែទាម ហើយយកខ្សែដែលចងជាប់នឹងចុងមែកទាំងពីរទៅចងនឹងក្បាលជំរៀវទាំងសងខាងខ្សែនេះហៅត្រ-ចៀនគាំ ទឹមគាំហើយសត្វក្របីគោនោះស៊ាំដើរទៅពំនូកកណ្តាប់ដែលពូនទុកនោះ លុះបរទៅដល់ហើយបន្ទិលគាស្រូវបួលក៏លើកកណ្តាប់អំពីពូកនោះម្នង ១ ដំបូកទៅក្នុងគាំវិញដាក់យកក្បាលកណ្តាប់ចេញទាំងសងខាង ដល់ផ្ទុកបានស្មើនឹងសសរគាំហើយក្រោយនេះត្រូវផ្ទុំបែរក្បាលកណ្តាប់ទៅមុខទៅក្រោយ ១ ស្មើ ដាក់បែរទៅសងខាង ១ ស្មើដាក់ទៅមុខក្រោយផ្ទុយគ្នាដូច្នេះប្រយោជន៍កុំឲ្យកណ្តាប់ជ្រុះពេលបរគាំទៅ ទុកជារណាក់បែបណាក៏មិនធ្លាក់កណ្តាប់ដែរ កណ្តាប់នេះដឹកម្តងបាន ១ ប័ន ២ ប័នឬ ១០០ កណ្តាប់តាមកំឡាំងក្របីគោខ្សោយខ្លាំង ហើយបើបានដឹកមកដល់លានហើយត្រូវរើកណ្តាប់ចុះរៀបធ្វើជាចុងហើរទៀត របៀបរៀបចុងហើរនេះ បើមានវែងបណ្តោយប៉ុន្មានក៏រៀបឲ្យផុតលាននោះទៅរៀបឲ្យប្រវែងខាត់លានខ្វាង រៀបយកក្បាលចេញ យកចុងចូលជួររៀបពូនជ្រុងដែរ ថ្ងៃកណ្តាលនេះរៀបវែងឲ្យផុត ១ បណ្តោយលាន រៀបពេញ ១ ស្មើហើយរៀប ១ ស្មើទៀតប្រហែលជាស្មើក្បាលបានហើយ

បើមិនអស់កណ្ដាប់ទេ ក្រោយនេះរៀបតែមួយចំហៀងគឺយកចុងកណ្ដាប់ទល់នឹងចុងហើយយកក្បាលកណ្ដាប់ចូលទៅក្នុងលានរៀបហែ ឱ្យស្មើគ្នានឹងចុងហើរ ប៉ុន្តែនៅ ១ ជំបនឹងផុតត្រូវរៀបក្បាលកណ្ដាប់ចេញ របៀបរៀបនេះដូចយើងរៀបៗសម្រែតដូច្នោះ ដែលរៀប ១ ចំហៀងក្រោយនេះ គេហៅថា ១ ផ្លូក ព្រោះរៀបផ្លូកទៅលើចុងហើរ បើរៀប ១ ផ្លូកមិនអស់ រៀប ១ ផ្លូកទៀតទាល់កាលណាអស់កណ្ដាប់ ប៉ុន្តែ ១ ផ្លូករៀបឱ្យខ្ពស់ជាងមុនបន្តិច ១ ដល់ក្រោយមកកណ្ដាប់ប្រក់តាំងពីចុងហើរសង្កត់ក្បាលកណ្ដាប់ពីតាឡើងទៅដល់ផ្លូកក្រោយបង្អស់ផែង របៀបប្រក់នេះដូចគ្នានឹងប្រក់ក្បឿនដែរ ហើយបើមានភ្លៀងមកពីបើមេក៏មិនទទឹកដល់ក្នុងទេ ត្រាន់តែទទឹក ១ ស្មើរលើប៉ុណ្ណោះ របៀបរៀបតាំងចុងហើរ ទាំងផ្លូកផង រួមហៅថា ជីមកណ្ដាប់តែម្យ៉ាង ។

## អំពីការបោក

ស្រូវនេះខ្ទះដីតឱ្យហើយទើបបោក ខ្ទះដីតបណ្ដើរបោកបណ្ដើរ របៀបបោកនេះ ជញ្ជូនកណ្ដាប់មករៀបនៃរនៃហាចំនួន ៥ ជំបហើយរៀបឱ្យខ្ពស់ឡើងទាល់តែប ១០០ កណ្ដាប់ ដូចរបៀបពូន ១ ចំហៀងក្លាក់ដែរ បើអ្នកបោកប៉ុន្មាននាក់ក៏រៀបកណ្ដាប់ប៉ុណ្ណោះព្រនូក ហើយយកក្តារបោកមកដាក់ប្របនឹងព្រនូកកណ្ដាប់នោះ យកកំបៀតកៀតកណ្ដាប់

មួយ ១ កណ្ដាប់បោកទឹកគ្រាបោក ៗ បាន ៣ . ៤ គូក ត្រូវបង្ហើបតំបៀត យកម្រាមដៃដែលក្ដាប់តំបៀតរេះកណ្ដាប់ឲ្យវិលទៅម្ខាងហើយបោក តទៅទៀត ប៉ុន្តែការរេះកណ្ដាប់ត្រូវរេះឲ្យរហ័សបំផុត នឹងដៃដែលរេះ កណ្ដាប់ ទីងដៃដែលបង្ហើបតំបៀតត្រូវឲ្យទៅព្រមគ្នា បើមិនដូច្នោះទេ គ្រាន់តែបង្ហើបតំបៀតកណ្ដាប់ក៏ធ្លាក់ចុះហើយ ពិបាកលើកឡើងកណ្ដាប់ ឡើងទៀត របៀបបោកត្រូវបែរមុខទៅបណ្ដោយខ្យល់ហើយដាក់គ្រារ បោកបៀនទៅក្បាលលានបន្តិច កុំឲ្យចំពាក់កណ្ដាលលានរ៉ែក្រងខ្យល់ បក់មកខ្ទាំងប៉ុនគ្រាប់ស្រូវផុតទៅប៉ុនណាន បើបោកអស់ ១ លី គឺ ១០០ កណ្ដាប់ហើយត្រូវខ្ទារយកសុំកទីងស្នូងស្រូវដែលបោកដាច់នោះចេញ មួយ គឺយកទៅនាស់ខ្ទារតែខ្ទារជំបូងត្រូវខ្ទារឲ្យស្រាលដៃ គឺខ្ទារមួយបន្តិច ៗ តែខ្ទារច្រើនគ្រាប់ស្រូវលុបទៅលើសុំកទីងស្នូងស្រូវបាក់អស់ មិនស្រូវ បានស្អាតទេ ខ្ទាររួចហើយត្រូវយកអំបោសៗ មួយទៀត ឈ្មោះនេះ ពាល់ឈលណាបោកអស់ស្រូវ ៗ

## បោកបោរ

គេយកក្រលៀមទៅពាត់ស្រូវឲ្យរបៀតទៅតល់ក្តុំ ៤ . ១០ ក្តុម ករទុក ១ ដុំ ៗ អ្នកណាកាត់ក៏បេះតែកាត់ទៅ អ្នកណាបោក យកបោរ ទៅឆ្នូងដែលកាត់នោះ ហើយយកតំបៀតក្បៀតស្រូវដែលកាត់ករទុក ១ ដុំ ៗ នោះយកទៅបោកក្នុងបោរ ដល់បោកបានគ្រាប់ស្រូវច្រើនកើប

ចេញហាក់កន្ទិតខ្ទួលម្ដង ហោះហើយមួយពេចខ្ទង់ គួសហោរទៅហោត ១ កន្ទង់ទៀត កាត់ហោរនេះគេមិនបង់ដូចប្រែតទេ គេត្រាន់តែកាត់គរ ១ ជុំ ៗ ចុំណោះ របៀបហោតហោរនេះ ខែមិនស្រូវមានហោតទេ មាន តែយួននិយមហោតប្រែន ។

## បញ្ញាន់

របៀបបញ្ញាន់ គេយកស្រូវរៀបឲ្យចំកណ្ដាលលានចំនួន ១ ខុប មូល យកគល់ចុះយកចុងឡើង ហើយដញ្ញូនកណ្ដាប់មករៀបព័ទ្ធជុំវិញ យកគល់ចុះដូចគ្នា ១ ជុំកាត់បំណងម្ដងៗ ទាល់កាលណារៀបហើយ របៀបរៀបចុំនាន ១០០ ឬ ២០០ កណ្ដាប់ក៏បានដែរតាមត្រូវការ ដល់ រៀបកណ្ដាប់ហើយ យកឈ្នួរបង់ក្រប៉ឹងរោធឲ្យជាប់គ្នា ប៉ុន្មានក៏បានដែរ ហើយបារោយលើស្រូវដែលត្រូវបញ្ញាន់នោះ បរិវេលជុំវិញត្រង់ការបម់នោម បើត្រូវទាន់ៗ បើមិនទាន់ក៏ហោលទៅក្នុងស្រូវនោះចុះ បញ្ញាន់ឲ្យទក់ បន្តិចហើយយកឈើ ១ ដែនចុងបន្តិចទន់ត្រាយដូចដងវែកសំរួចចុងឲ្យ ស្រួចផ្ដើះបញ្ចើបស្រូវដែលបញ្ញាន់ហាប់នោះឲ្យធូរឡើងវិញ ត្រង់ណាដេះ យកនោសខ្វាររោលចេញ ណាមិនទាន់ដេះបញ្ញាន់តទៅទៀត ទាល់ កាលណាដេះអស់ ហើយខ្វារបំបើងរោលចេញឲ្យអស់ ហើយរៀប បញ្ញាន់តទៅទៀតជាថ្មី ទាល់កាលណាអស់របៀបបញ្ញាន់នេះ មិន ចាប់ត្រូវបំបើងដូចបោកក្ដាររទេ ព្រោះគ្មានអ្នកត្រូវបំបើងទៀត ។

## ត្រជុះចំបើង

របៀបត្រជុះចំបើង អ្នកធ្វើស្មានមើលប្រហែលជុះហើយត្រូវដកកណ្ដាប់ទៅបុកលាន មានអ្នកចាំទទួលត្រជុះ ដំបូងចាប់ក្បាលកណ្ដាប់ក្រឡុះបុកកណ្ដាប់ឲ្យជ្រុះស្រូវសិន ហើយប្រែចំណងទៅខាងបុងយកគល់កណ្ដាប់ទន្ទិចទៅក្នុងដីឲ្យជ្រុះស្រូវអស់ ហើយយកទៅគរទុក ១ ដុំ ពេលចំនោះផ្ទាំងចំបើងទៅរៀបធ្វើជាព្រនូក ១ ខ្ពស់ស្រមាប់ឲ្យគោក្របីស៊ី ធ្វើអ្វីតាមត្រូវការដែលធ្វើបាន ។

បើបោក ឬបញ្ចាន់អស់កណ្ដាប់ហើយ ត្រូវរៀបចំរោយស្រូវនោះតទៅ ។

## អំពីររៀបរោយ

ពេលរោយនោះ បើមានខ្យល់ល្អយកកញ្ញើកើបស្រូវឈររោយនៅដីក៏បានដែរ ឬយកក្ដារដំកល់ឲ្យខ្ពស់ឡើងបន្តិចហើយចាក់រោយទៅក៏បាន បើមិនសូវមានខ្យល់ ឬស្រូវនោះមានចំនួនច្រើនឈររោយនៅដីយូរពេក ត្រូវធ្វើកន្ទេងរោយឲ្យខ្ពស់ទើបរោយបានឆាប់ គឺធ្វើពន ១ ឲ្យខ្ពស់ចំនួន ១ ទទូងដៃឲ្យម្នាក់ឡើងឈរលើពននោះ មានអ្នកកើបស្រូវបន្តទៅឲ្យអ្នកឈរនៅលើពនចាំតែលើកចាក់ៗរោយ ថែមនេះបើមានអ្នកកើបច្រើនរោយ ១ ថ្ងៃបាន ៤-៥ រយថាំង ប៉ុន្តែត្រូវចាត់ឈរកាន់អំបោសនៅប្រែបនោះផង បើឃើញមានសំរុងឬស្លឹកស្រូវធ្លាក់មកត្រូវយកអំបោសត្រាំសភាយ កុំឲ្យយូរ ស្រូវក្រោយធ្លាក់សង្កត់មកលើបោសមិនបាន ។

# របៀបភាល

ស្រូវផលក្រោយហើយ ប្រមូលគ្រាប់ពូជទុកសំយកចំពោះ (គៅ) កាល់គឺ ២ ចំពោះ ត្រូវជា ១ ថាំង កាល់ពេញចំពោះបាក់ទៅក្នុងគញ្ចប់ចំនួនជា ៣ ថាំងតែ ទៅបាក់ក្នុងដោតមុជក្នុងកម្ពង់ កាល់យាំងនេះដើម្បីឲ្យផងបាធ្វើស្រែ ១ ឆ្នាំ តើបានចុះនានយេថាំង បាន ៨០០ ឬ ១.០០០ ថាំងផាដើមខ្លះ គបង់ឲ្យផងចំនួនបាបតែកាល់ ១ ថាំងហើយថ្លឹងមើល តើបានប៉ុន្មានកិឡូ បើ ១ ថាំងបាន ២០ កិឡូ ហើយកាល់បានប៉ុន្មាន ១០០ ថាំង ក៏គិតកិឡូ តាមចំនួនស្រូវនោះទៅ ។

ទីបំផុតរបស់រឿងដែលតែងអំពីការធ្វើស្រែ របស់ខ្ញុំគេម្ដជាក្រោម ខ្ញុំព្រះករុណាខ្ញុំបាទសូមអភ័យទោស ត្រង់ឈ្មោះរបស់សម្រាប់ធ្វើស្រែ ចំនួនទៅហារដែលប្រើក្នុងផ្លូវនៃរឿងនេះទាំងអស់ គឺប្រើតាមភាសារបស់ស្រុក ។

ហេតុហ្នឹង បើឃើញមានខាតខុសត្រង់ណា មេត្តាជួយបំពេញឲ្យផងផង ដើម្បីជាប្រយោជន៍ដល់អ្នកដែលមានអាជីវៈក្នុងការធ្វើស្រែតទៅ ។

អាចារ្យ ឱញ-ប្រាជ្ញ

អាចារ្យ ពុទ្ធសាសនបណ្ឌិត្យរង ខេត្រឃ្លាំង

ប្រចាំដែនកូស័ងស៊ីន

# រឿងកោតគុលកុមារ

## អ្នកឧកញ៉ា ព្រះឃ្លាំង នង រៀបរៀង

(តមក)

ទើបអស់ទេវតា ជំនុំគិតគ្នា ព្រមប្រែព្រះញាតិ មួយមកកាឡា ប្រែជា
ស្ដេចនាគ ហោះចុះសង្កាត ដល់ឆ្នេរជលសា ។ នាគបង្ហូលដល់
ទៅចៅកោតគុល ទើបស្រដីថា ខ្ញុំសង្កាតមក ស្វែរកប្រាថ្នា សុំសុខា
បរិភោគសោះឃ្លាន ។ ព្រះពោធិសត្វ មហាបុរសរត្ន ស្ដាប់ហើយ
ឆ្លើយថ្កាន ថាហៃស្ដេចនាគ សង្កាតរុកពន ចុះមកចង់បាន បរិភោគ
ទោបក្ត ។ ខ្ញុំព្រមឲ្យអ្នក យកបរិភោគភ័ក្ស បំអែកតាមតែ ចំណង់
ប្រាថ្នា អ្នកអាសូរណា នាំផ្លូវទៅឯ សត្តបុរី ។ ល្បិតខ្ញុំក៏ព្រា
ព្រាត់ព្រាសករិយា ឃ្លាតនៅទូរទៅ ពុំជិនខាតា យាត្រាទៅខ្វី បូអន
ប្រណី នាំណាខាតា ។ ទើបស្ដេចនាគឆ្លើយ ថាអត្មាសំអើយ កុំព្រួយ
ចិន្តា ខ្ញុំខិននាំមុខ វាលកុណ៍យាត្រា ថាហើយហាក់ជា បរិភោគ
ផ្កែនោះ ។ វិស័យតាមផ្លោយ ចំប៉ាំងមិនឲ្យ ឃើលជាក់ចំពោះ លុះព្រឹក
ស្រាន់ស្រេច ទើបស្ដេចនាគនោះ នាំអ្នកត្រើបញ្ចោះ ដើរដោយមាគ៌ា ។

### បទព្រហ្មគីត

កាលណោះពោធិសត្វ បុរសរត្នថ្លៃសោភា សិហនាទយានយាត្រា
ត្រើបដើរតាមស្ដេចនាគនោះ ។ បូលភ្នំព្រៃព្រឹក្សា ដោយចព្វតា

ផ្ទះជ្រោយជ្រោះ លុះលេចផល់ព្រោះ យល់សត្វសត្វនៅដោយកាល ។ រមាំងៗមៀង មើលចាល់កៀនគូត្រកាល ដីស្មៅនៅកណ្ដាល វាល ព្រោះថ្លា ។ រមាសៗដើរ ដើរមៀងមើលរកបទ្វា បរិភោគឈើ ពេក ឈរចាំដោយម្លប់ព្រៃផ្គុំ ។ ដំរីៗស្រប់ ស្រប់ក្រោមម្លប់ដើមធ្នុំ បេះបោចលេចល្អិត ដំរីបានបរិភោគ ។ ក្របីៗព្រៃ រកវៃរកកៀនគូក ថ្ងបថ្ងីរគោគ្កា ត្រយឺងប្លាសក្រពៅទ្វី ។ ខ្នាយៗស៊ីង ពាក់ ពួនពីរខេចំណី ប្រប៉ិចត្រយងស្មៅទ្វី ដើរក្រោមម្លប់ៗ ខ្សែ ។ ខ្នេងៗសោត ដើរលេងលោតប្រឹងប្រាណប្រែ ធីស្មៅល្អាស់ បានថែរ មៅឈរឈប់ម្លប់ខ្នោរ ។ ថ្កៃព្រៃៗព្រីស ដេញដោម ប្រើសនៅកណ្ដាល ទាំងធីជាអាហារ ហើយមៅឈប់ម្លប់ថ្កៃស្រែន ។ កោព្រៃៗព្រោះ ដើរបន្ទោះដោយពលវៃង ធីស្មៅហើយលោតលេង នៅក្រោមម្លប់ៗគោម្លួយ ។ បបកៗនៅ ដើមបៅឈរផ្នើយ ផ្ទប ព្រលៗព្រួយ ឈ្លូសធីមើមត្រកាញផ្ញប ។ ខ្លាធំៗ ក្រាប ក្រាប ស្រពាបនៅផ្ទប់ តយឃ្លាំចាំចាប់ផ្ទប ផ្ទាប់ខាងដើមដើមដៃខ្លា ។ កាន់តាងៗ កៀង តួមត្រមៀងគេកោក្ដា អណ្ដាប់អណ្ដាយគ្នា ឈប់ នៅម្លប់ៗ ដើមកុល ។ ស្វាព្រាហ្មណ៍ៗព្រៃ ក្លួចរំពៃតពស្គុផល ផណ្ដើមគ្នារបល់ ធីផ្លែស្វាយៗមេនព្រួល ។ ព្រះពោធិសត្វយល់ សត្វសែនសល់អន់អាក់អួល ទរាំងរំជួល គិតទៅដល់វាជាយ ។

ជាទុក្ខខ្លួនទេ អស់សត្វសត្វកៀនក្បាំ ដណ្ដើមរកគោគ្គា ទន្ទឹមចាំនឹង
ឈ្លោះលើគ្នា ។ មួយទៀតនៅតបង់បង់ ខ្លួនរវើរពេញពិសី ឃ្លាឃ្លាត
ទៅទូទៅ មិនមូលមិត្រជួបសត្វសត្វ ។ ខ្ញុំភ្ញាក្តានយានយាត្រា កូនព្រៃ
ស្ងៀមស្ងាប់ស្ងាត់ ៧ យោជន៍ទៀតទាត់ លុះព្រលប់ព្រះសុរិយា ។ បរ
ក្បុលឈប់សម្រាន្ត នៅក្រោមហិនម្លប់ព្រៃ ឯភ្នាកនោះឃើញជា មរណ៍
ក្បុណក្បាយជីពជន្មជាតិ ។ ព្រះពោធិសត្វ មៀនមើលយល់ខ្លួ
ស្តេចភ្នាត ក្បុណក្បាយស្ងប់សាកសាក អ្នកទៀនព្រៃយព្រះចិន្តា ។ ខ្ញុំ
ទ្រង់ព្រះនេត្រ ពិលាបថ្លៃនុំខ្ញុំញុំជា ទុក្ខនៅពិតា ឬបម៉ូបន័យ
អកិត្ត ។ សង្ឃឹមត្នាតបក្សា នាំយាត្រាត្រឡប់ធាប់ កំឡុងត្រាតមិញស្ងាប់
ស្ងៀមអស់អារោសោចស់ល់ ។ ទុកម្មវិបាកបន ខែនរៀងរាំ ទុក្ខទល់ ឯកអង្គ
ឯងអំពល់ អំពីព្រាត់ប្រាសប្អូនភ្នា ។ ទុអង្គអញឯកោ អនាថាគួនអញ
ឥតអង្គអ្នកឯណា មួយត្រាំនពីនត្រាំងត្រស័យ ។ មានតែគុណព្រះពុទ្ធ
ជាតិជាមកុដទាំងកពៅត្រៃ គួរគុណព្រះធម៌ថ្លៃ ខ្ទើរគុណព្រះអរិយសង្ឃ ។
ជៀនជួយជាទីពឹង ជាពំនឹងពំនាក់អង្គ ទើបទុកលើកកផ្ទន់ ដាក់លើសិរ-
សីស្បូត្រថា ។ ពុទ្ធោមេ នាថោ[១] ឧត្តមោមង្គលា[២] ធម្មោ-
មេនាថោ[៣] សរណំមង្គលំ[៤] ។ សង្ឃោមេនាថោ[៥]

---

១ ប្រែថា ព្រះពុទ្ធជាទីពឹងរបស់ខ្ញុំ ។ ២ ជាមង្គលខ្ពង់ខ្ពស់បំផុត ។ ៣ ព្រះធម៌ជាទីពឹងរបស់ខ្ញុំ ។ ៤ ជាទីពឹងជ័យមង្គល ។ ៥ ព្រះសង្ឃជាទីពឹងរបស់ខ្ញុំ ។

ដំណេះបុញ្ញក្ខេត្តំ(១) សព្វទុក្ខក្ខយំ(២) សពេតាវិណា-
សន្តិ(៣) ។ ពោធិសត្វការនោ ព្រះធម្មាលុះយាមបី អ្នកនិទ្រានៅដី
លក់លុះស្រានព្រះបុរិយោ ។ ទើបទេវបុត្រមួយប្រាណ ជាសន្ដានញាតិ
ពន្សា និរមិត្តប្រែអាត្មា ជាក្អែក ១ ហើរមកដល់ ។ ពោលពាក្យស្រដីថា
ហៃអ្នកមានពនិមិល ខ្មោចភ្នាក់នេះនៅបល់ ខ្ញុំសុំបរិភោគសោះឃ្លាន ។
ព្រះពោធិសត្វឆ្លើយ ថាក្អែកអើយបើអ្នកមាន ប្រាថ្នាចិត្តបង់បាន
បរិភោគខ្មោចភ្នាក់នោះមិញ ។ យើងព្រមឲ្យអ្នកនី ជាចំណីមិញ
កុំម្ញេញ ហើយអ្នកជួយនាំអញ ឲ្យដល់សត្តកូដបុរី ។ ក្អែកស្ដាប់
ហើយហើរក្ដាន់ ទៅទំខាងក្បាលបក្សី ចំបាំងធ្វើជាធី ស្រែបនាំអ្នកបរ
យាត្រា ។ ចូលក្នុងព្រៃស្រានស្រាន សិងគាងថ្មសិលា មានទឹក
ជ្រោះរេងថ្លា ដោយមាគ៌ាវៀងពបទៅ ។ អ្នកឈប់ខាងគង្គា ហើយ
យាត្រាត្រេចសំដៅ ។ ចូលក្នុងព្រះព្រៃជ្រៅ យល់សុខ្ខសិងសត្វ
បក្សា ។ កៀងឆ្កូទាំងឈ្មោបញ្ជី ហើរកេសុីពស្ដុផលា បណ្ដើរ
បន្ទ្រា ទំដោយដើមព្រឹក្សសោត ។ មាក់ផាកប៉ោលគោកទំ
ទំហើយយំហើរលេងលោត កន្ទ្រាញ់កេសកែវគោជ្ជ សត្វកន្ទ្រាញ
កន្ទ្រនទំ ។ ក្អែកព្រាប ១ ព្រៃ ទៅកេទំនៅទ្រូទំ សេកយា ១ យំ

---

១ ជាស្រែបុណ្យដ៏ប្រសើរ ។ ២ វិទុក្ខភ័យទាំងពួង ។ ៣ វិពេតទាំងឡាយតែងវិនាស
បាត់បង់ទៅ ។

ហើរទៅទំដើមត្រសេក ៗ ទ្រើងទ្រើងសំណាក់ ពួនពីងពាក់ជា
ដំណេក ដើរតាមតាមព្រៃដេក ដើមក្រសាំងក្រសាងទៅ ៗ
ចេកចុំៗទេស ដើមការពេសកន្តិកខ្ចៅ ទទ្ទីងទទ្ទាយទៅ ទំពាប់បឹត
ពីស្តុកោក្តា ៗ ទៀនទឹកដើរទៀនទំ ទំហើយយ៉ំគគ្រូប ពញាក់ទំពញា
ដើមនាងខ្នួននាងខ្នួននៅ ៗ សសេះៗសោត ទំលេងលោតហើយ
ហើរទៅ បពាំកតាបបទៅ ដើមមហាហង្សហង្សនៅទិត្យ ៗ ពាល់
ចាបចាបទឹកទៅ ទាំងខ្ទុះទៅទំមូលមិត្រ ដើរគោស្តេចគាលិដ្ឋ ទៅទំ
នៅនៅក្តា ៗ ទុទេញ្ញកទុទ្យូលោត ខ្មៀ ខ្វារសោកគោកាក្តា សៃស្មាប់
ស្មោញពេក ទំសំកុកសំកាំងស្លាប ៗ ដៃខ្លាសត្វទ្រទាក់ ខ្លាសំណាក់
ក្រញ្ញកុនក្រាប ស្ទាំងស្ទុះផ្ទោះទទ្ទាប ទទ្ទីងទៅទំទទ្ទា ៗ ខ្ទីងគង់
ខ្ទីងស្រាកស្រែក ទំលើមេគគ្រូប ដើមប្រពេចបង្ក សត្វប្រពេច
ទំលោតលេង ៗ កាទុដ្ឋាៗទំ ដើមទទំកាទុដ្ឋង កុកក្រកកុកក្រោង
ក្រែង ទំដើមព្រាងដើមគ្រលគ្រូង ៗ ចាស្កាចស្កាដេក ជាដំណេក
នៅបមបុង ទៀចទៀតពាសទទ្ទុង ទុងពាមទៀតទំស្រមាទ្ទ ៗ
ក្រក្រាយក្របក្រពក្រៀល ទំសសៀសេសិតប្រាណ ដើមមទដើម
មៀនមាន សត្វមៀមមុំទំទិត្យនៅ ៗ ពុលពកពូកែទំ ទាំងពួយ៉ំហើយ
ហើរទៅ តាបបៀចក្រពាសនៅ ដើមក្រញ៉ាកបញ្ញាសព្រៃ ៗ បង្គរៗ
គ្នាគ គ្នាគទំព្រាគគយរៃត រូសកក់គេកកំងរៃ រៃគណ្ដឹងគណ្ដូបយ៉ំ ៗ

រំពេកនៅរំពាក ពាក្រែកពាកចាប់ខ្ទំ សំរោមមាន់ទាទំ ដើមថ្កុំ ចិនចិនហោះនៅ ។ ព្រះពង្សពោធិសត្វ ត្រាច់ដើរកាត់ក្នុងព្រៃព្រៅ យល់សត្វសត្វនៃចនៅ នៅដោយឡែកនិងដោយគ្នា ។ រងំស្លូលរងំគា-ខ្ទរះ គិតស្រណោះដល់ជាយា ជាទុក្ខសព្វបក្សា បក្សីសឹងពុំព្រាត់ប្រាស ។ ចំទឹមចំមចាំនិងប្តូ មេពង្សរៀតែប្តីមាស ឃ្លាឃ្លាតទៅនិងស ពោះចន់ចង់បាត់ពុំយល់ ។ អ្នកគន់ៗគិតទៅ ព្រះប្អូនពៅថ្មើមនិមិល ដោះព្រោចអស្សុជល ស្រក់សស្រាក់ដោយទោត ។ លុះសូរ្យសាយ-ណ្ហ ពាចទៅឯបស្ចិម ថ្ងៃនោះអ្នកយាត្រា បាន ៧ យោជន៍កំណត់ ។ ក្អែកនោះធ្វើជាមរណ៍ អន្ធអន្ធការបាគដ នាកាលអស្តង្គត ពន់ព្រលប់ព្រះសុរិយា ។ ព្រះពោធិសត្វថ្ងៃ យល់ក្អែកក្សៀយជីពដទៃ រងព្រៃព្រះទ័យា ឯងអនាថាថៃថប់ ។ សង្កេតអទិច្ចា ព្រះកន្ត្រាស្ងូតស្ងៀមស្ងប់ កានោពីព្រលប់ ដល់យាមបឋមគន់ក្រោ ។

បទភុជង្គលីលា

១ លុះព្រានព្រឹកព្រាងស្ហ្រា ខៀវខៀបខេត្ត មួយសឹងសន្ទាន ។ កាឡាកាត្តាប្រែប្រាណ ជារុយមួយមាន កំឡាំងស្មើខ្យល់ ។ ហើរហោះផ្លេតផ្ដាះមកដល់ ជួបទៅគោតកុល ពេពាក្យសួរថា ។ ហៃខ្ទង់រវង្សសោកា មិនមានគ្នីគ្នា ដើរតែឯងអង្គ ។ ចិន្តាប្រាថ្នាហេតុបង់ យាត្រាត្រែបត្រង់ ទៅទីឋានណា ។ ពោធិសត្វវិសេសថា

រុយហើយកក់ហោ អន្ទអញព្រាត់ទៅ ។ អញមកតាមរកសំពៅ ឲ្យដល់
ឆានទៅ សត្តបូជុរ ។ រុយឯងចូរឈ្មោលប្រណី ជួយនាំផ្លូវពី គាយ
ឲ្យអញដល់ ។ ឲ្យបានរួមហ៊ានមណ្ឌល- នឹងនាងនិមិល ដូចក្តីប្រាថ្នា ។
រុយស្តាប់អ្នកប្រាប់ឆ្លើយថា ឆាវខ្ញុំជានា ទឹងនាំអ្នកទៅ ។ ហើយ
ហើរបណ្តើរបមទៅ ចរចូលព្រៃព្រៅ ដោយជាខមាត ។ ផ្លូវឆ្ងាយ-
បម្ពាយយាត្រា ថ្ងៃនោះគណានា ៧ យោជន៍គត់ ។ សុរិយាលា
កំណត់ អស្ដង្គត ឆ្លងឈប់និទ្រា ។ រុយនោះចំពោះឆ្លើយថា
ក្បែរក្បែរមរណា បាត់បង់ជីវី ។ លុះព្រាងបំព្រាននៃ ស្រូវ
សែនអំពី ទិទិសបូពា ។ ឥឡូវទ្រអង្គផ្គុំកាឡ ប្រែប្រាណជាតិជា
អំពិលអំពែក ។ ឆ្លើរស៊ើល្ហែក ល្អព្រែចំខ្សែក ក្តីដូចភាព ។
ថ្ងៃសុំធ្លាក់បុរោហិតសូត្រ មកដល់ព្រះមហា- បុរសរុក្ខ ។ ក្រឡឹង
ផណ្តឹងទៅថ្នាក់ ថាអ្នកដើរឆោត ទៅទិហាខណា ។ គោតកុល
និមិលថ្លៃថ្លា យល់ហើយនិតថា អំពិលអំពែក ។ ក្តៅព្រែប្រែពិចខ្សែក
ស៊ើក្តីដូច នេះសមខេត្តា ។ ទ្រង់រឿងនិរម៉េ ក្រកាឡ ទើបអ្នកឆ្លើយថា
ខ្ញុំនឹងត្រោះទៅ ។ ត្រែបត្រង់ព្រមផ្សំសំពៅ ករយោ ខ្ញុំទៅ សត្តបូជនគរ ។
សក្តាខេរសាខរ នាំអ្នកចេញចរ ដើរដោយផងព្រៃ ។ ខ្ញុំឃាត
សង្កាតពេចព្រៃ រសៀលល្ងាចថ្ងៃ នោះអ្នកដើរដល់ ។

(នៅមាន)

# សាមគ្គីកថា

ជាឱវាទកថា របស់ព្រះបាទព្រះមហា អសុ-កោ ( គោវិទគោ )

អាចារ្យបង្រៀនសាលាបាលីរង វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយគោរព ។

លំដាប់នេះ នឹងសំដែងអំពី ដើមកំណើតនៃសន្តិសុខក្នុងលោក ដោយសង្ខេបតាមកាលវេលាដូចតទៅនេះ ។

សុខា សង្ឃស្ស សាមគ្គី « សេចក្តីព្រមព្រៀងគ្នារបស់ពួកក្រុមនាំឲ្យកើតសន្តិសុខ ( ក្នុងលោក ) » ។

ពុទ្ធភាសិតនេះ មានសេចក្តីដែលគួរដកស្រង់យកមកប្រែ និងអធិប្បាយ ៣ បទ គឺ: សាមគ្គី ១ បទ, សង្ឃ ១ បទ, សុខ ១ បទ ។

សាមគ្គី ប្រែថា «សេចក្តីព្រមព្រៀងគ្នា, ដំណើរស្រុះស្រួលមូលមិត្រនឹងគ្នា, រួបរួមគ្នា, ចងបាច់គ្នា, ពួតដៃគ្នា, ត្រូវគំនិតគ្នា, មានចិត្តស្មើគ្នា, មានអធ្យាស្រ័យត្រូវគ្នា, ទុកចិត្តគ្នា, មិនបែកចិត្តពីគ្នា, មានចិត្តស្មោះស្ម័គ្រជួបគ្នា, មានករណីយកិច្ចត្រូវគ្នា, ទុកចិត្តបិទជួញគ្នា, ចុះសំរុងគ្នា, មានមេត្រីចិត្តលាយចូលគ្នាដូចទឹកនឹងទឹក ឥតភាសល់ដែនខ្វែងគំនិតគ្នា, មិនប្រកួតប្រជន់, មិនបង់គំនុំ,» ។

សង្ឃៈ ប្រែថា «ពួក, ក្រុម, ប្រជុំ, ហ្វូង, បន, កុល, គណៈ, និចយ, សមូហ, បរិស័ទ» ។ តែបើតាមព្រះវិន័យ សំដៅយកបព្វជិតតាំងពី ៤ រូបឡើងទៅ ។

សុខៈ ប្រែថា «សេចក្ដីសប្បាយ» ធម្មជាតខាងសោះ ដែលជារបស់គួរស្រឡាញ់, ដំណើរស្រួល, រីករាយ, ស្រណុក, មិនក្រវល់ក្រវាយ, មិនរឹតត្បិត, មិនជ្រួលច្របល់, មិនក្ដៅចិត្ត, មិនក្ដៅក្រហាយ, មិនស្ដាយក្រោយ សេចក្ដីសម្រាន្ត» ។ តែក្នុងទីនេះ សំដៅយកសន្តិសុខ គឺសេចក្ដីសុខ ស្ងប់ ឬសន្តិភាព ដែលជាទីប្រាថ្នា របស់លោកទាំងមូល ។

កាលបើរួមសេចក្ដីប្រែនៃពុទ្ធភាសិតទាំង ៣ បទនេះ ទៅជាប្រយោគ ១ ទៅ នឹងឃើញច្បាស់ថា សាមគ្គីជាសុខហេតុ គឺថា បើសាមគ្គីរបស់ពួកក្រុមកើតមានឡើងហើយ សន្តិសុខជាទីស្រឡាញ់ ក៏នឹងកើតឡើងយ៉ាងងាយ ដោយមិនបាច់វិធីយ៉ាងផ្សេងដទៃក្រៅអំពីនេះ ឡើយ ។

សាមគ្គីនេះ ចែកចេញជា ៣ យ៉ាងគឺ កាយសាមគ្គី «សេចក្ដីព្រមព្រៀងគ្នា ដោយកាយ» ១, វចីសាមគ្គី «សេចក្ដីព្រមព្រៀងគ្នា ដោយសំដី» ១, ចិត្តសាមគ្គី «សេចក្ដីព្រមព្រៀងគ្នាតាមផ្លូវចិត្ត» ១, ។

ការស្រុះស្រួលគ្នាទៅវិញទៅមក រវាងពួកគណឬសង្គម រហូតដល់លោកជាទីបំផុត មិនប្រែះបាក់បែកគ្នាជាពួកបក្ស រមែងជាបច្ច័យ

ឲ្យបានទទួលសន្តិសុខ និងសេចក្តីចំរើនរុងរឿងឥតអាក់ ឥតមានឧបសគ្គអ្វីមករាំងបានឡើយ ។ សាមគ្គីនេះ ទុកជាទីពឹងខ្លាំងមួយយ៉ាងសំខាន់ ដែលអាចជួយសាសនា, ប្រទេសជាតិ, និងលោកទាំងមូល ឲ្យបានចំរើនជាប់មាំស្ថិតស្ថេរ មិនឲ្យគ្រឡប់រវេរវាយ ឬវិនាសទៅបាន ។ បើសាសនិកជន ឬប្រទេសជាតិណា មានសាមគ្គីដុះដាលតាំងនៅជាប់មាំល្អ សាសនិកជន ឬប្រទេសជាតិនោះ នឹងបានសេចក្តីសុខចំរើនយ៉ាងអស្ចារ្យ ឥតមានអំណាចអ្វីទៅលុកលុយ ឲ្យសាបសូន្យរលាយរលត់បានឡើយ ប្រៀបដូចជាសរសៃអម្បោះតូចៗ តែគេយកច្រើនសរសៃវេញត្របាញ់ចូលទៅជាមួយគ្នា គេអាចយកអម្បោះនោះទៅចងដំរីជាដើម ដែលជាសត្វធំមានកម្លាំងច្រើនឲ្យជាប់បាន សត្វទាំងនោះមិនអាចទាញរើ ឲ្យដាច់ខ្សែអម្បោះនោះបានឡើយ ។ សម្បុរូបកាយយើងនេះ ដែលនឹងតាំងនៅ ឬចំរើនឡើងបាន ក៏ដោយអាស្រ័យសាមគ្គីរបស់ធាតុ ៤, អាការៈ ៣២ និងសរីរាង្គៈដ៏សេសដូច្នោះដែរ; បើរបស់ទាំងនេះមិនរួបរួមគ្នា មិនហុចឬមិនថែរថែមកំឡាំងដល់គ្នានឹងគ្នាហើយ រូបកាយយើងក៏លែងប្រព្រឹត្តទៅបាន ។

នៅក្នុងព្រៃ សត្វចតុប្បាទមានខ្លួនតូចៗមួយពួក ហៅថា ឆ្កែព្រៃ មានខ្លួនជាងឆ្កែស្រុកនៅទៀត តែវាមានសាមគ្គីស្រុះគ្នាជាបំផុត វាអាចចោមរោមទាំងខ្លាឬសីហៈ ដែលជាសត្វមានខ្លួនសម្បើមហើយកាចសា-

បករយ៉ាងនេះ ត្រូវបែងយកជាអាហារពុំបាន ខ្លាំងនឹងសីហៈ តែនឹងមានមហា-ភ័យដ៏ពន្លឹកអំពីខ្លាព្រៃជានិច្ច ។

ប្រមាថ, សង្ការ, ធណ្ឌារ, យំនឹងព្រមាទជាដើម អាស្រ័យការសាមគ្គីស្រុះគ្នា អាចធ្វើកិច្ចបេសក៍ ឲ្យសម្រេចតាមបំណងគ្រប់ផ្លូវបាន ទាំងនេះក៏ព្រោះសាមគ្គីជាហេតុ ។

ខ្លាព្រៃជាដើម ជាសត្វតិរច្ឆានមានអាយុខ្លី ឥតដែលមានសាសនាប្រដៅ ឥតដែលមានសៀវភៅក្បួនច្បាប់សម្រាប់មើល ទាំងគ្មានអ្នកប្រាជ្ញណាប្រដៅឲ្យចេះស្រឡាញ់រាប់អានគ្នា ឲ្យមានសាមគ្គីស្រុះគ្នាសោះ រាល់ចេះបណ្តុះសាមគ្គីនឹងគ្នាបាន ។ ចុះយើងជាមនុស្សជាតិត្រឡាំង?, មានសាសនាល្អសម្រាប់កាន់, មានសៀវភៅក្បួនច្បាប់សម្រាប់មើល, មានអ្នកប្រាជ្ញប្រៀនប្រដៅ, ទាំងមានជាតិជាអ្នកដឹងខុសត្រូវស្រាប់ ម៉េចក៏ទៅជាបណ្តុះសាមគ្គីមិនកើត? អ្នកដែលមិនគោរពសាសនាទៅចុះ យើងមិនបាច់និយាយដល់; ចុះប្រជាជនជាតិខ្មែរយើងដែលកាន់ព្រះពុទ្ធសាសនាទាំងស្រុង ម៉េចក៏មិនគិតដល់ពុទ្ធភាសិតត្រង់នេះផងសោះ? ម្តេចក៏ចំណោយឲ្យបែកសាមគ្គី ទៅជាពួកបក្ស គណៈនិកាយដូច្នេះ? គួរឬ? បើដូច្នេះតើ នឹងធ្វើឲ្យព្រះពុទ្ធសាសនា ចំរើនរុងរឿងដូចម្តេចបាន? ការខំប្រឹងជ្រោងព្រះពុទ្ធសាសនា និងប្រទេសជាតិឲ្យគង់ចំរើន ដោយប្រាសចាកឧបាយ រួមរួមបណ្តុះសាមគ្គីជាការផងអំពើ

ខុនដូចជាគេមកជីកឡាប់ទៅសួនច្បារញ៉ាំមកប្រើ រមែងប៉ះប្រទះនឹងខុបសគ្គនាំឲ្យលំបាកជាអនេក ហើយថែមទាំងឥតបានសម្រេចប្រយោជន៍អ្វីឡើយ ។

ក្នុងសម័យឥឡូវ ដំឡៃនៃសីលធម៌និងសាមគ្គីធម៌លេតខ្សត់ខ្សោយអស់ទៅ នាំឲ្យអស់សង្ឃឹម ក្នុងផ្លូវសន្តិសុខព្រមទាំងវឌ្ឍនធម៌ បើទុកជាខំប្រឹងប្រែងស្វែងរកដោយសតិបញ្ញាដ៏ល្អិតសុខុមយ៉ាងណា ក៏នៅតែកម្រនឹងធ្វើឲ្យកើតឲ្យចំរើនឡើងបាន ។

តាំងពីយូរយារណាស់មកហើយ ដរាបដល់សព្វថ្ងៃ លោកទាំងមូលកំពុងប្រឹងប្រែងរកមធ្យោបាយបង្កើតឲ្យមានសន្តិសុខ រហូតដល់ទៅបង្កើតឲ្យមានសមាគមសន្តិសុខសម្រាប់លោក ដែលហៅថា អង្គការសហប្រជាជាតិ; ប៉ុន្តែមកដល់ទីនេះថ្ងៃនេះ ស្មើតែមិនបានជួបប្រទះនឹងស្រមោលនៃសន្តិសុខសោះ ។ មិនមែនដោយការបង្កើនគ្រឿងអាវុធយុទ្ធភណ្ឌស្មុគស្មាញនោះទេ ដែលនឹងនាំយកមកប្រើបង្កើតជាបែបសន្តិសុខនោះ ។ បើលោកទាំងមូលនៅតែសង្ឃឹមលើកម្លាំងកងទ័ព ដែលមានសាស្ត្រាវុធយុទ្ធភណ្ឌយ៉ាងសម្បើមដូច្នោះ នានាជាតិអស់នោះ នឹងមិនផុតពីសេចក្ដីក្ដៅក្រហាយដែលចងពៀរខ្លួនឯងឡើយ ។

បើតាមច្បាប់ពុទ្ធសាសនាយើងសំដែងថា សន្តិសុខក្នុងលោកនេះនឹងកើតមានឡើង ក៏ដោយសារកម្លាំងនៃសាមគ្គីធម៌និងមេត្រីចិត្ត

ដំបាំសុទ្ធដំមានរបៀបបែបផែន ក្នុងមនុស្សម្នាក់ៗ និងមនុស្សទូទៅតែប៉ុណ្ណោះក្រៅពីនេះមិនមានឡើយ ។ បើពិចារណាឲ្យជ្រៅល្អិតល្អទៅគួរជឿយកជាការពិតបានណាស់ ។

ឯការប្រែធា ធាត់បែប រូបភាពអន្តរាយនៃសាមគ្គីធម៌នេះ កើតឡើងដោយសារហេតុច្រើនប្រការគឺ ដោយសារឧបក្កិលេស, ដោយសារអគតិ និងដោយសារទិដ្ឋិជាដើម ។ ហេតុទីមួយបានដល់

## ឧបក្កិលេស ១៦ គឺ:

១– អភិជ្ឈាវិសមលោភៈ សេចក្តីលោភចង់បានហួសទំនងឬបំពានលោភយករបស់គេ ។

២– ទោសៈ ប្រទូស្ត ឬបៀតបៀនជិះជាន់គេទាំងអំណាច

៣– កោធៈ ក្រោធខឹង ឬធ្វើទុក្ខបុកម្នេញគេ

៤– ឧបនាហៈ ចងក្រោធទុក ឬចងគំនុំ

៥– មក្ខៈ លុបគុណ ឬរំលើគុណគេ

៦– បលាសៈ វាយឫកស្មើ លើកខ្លួន ឬប្រណាំងកសេនា

៧– ឥស្សា ឬស្យាប្រណែនឈ្នានីសគេ មិនចង់ឲ្យគេមានបាន

៨– មច្ឆរិយៈ កំណាញ់ស្វិតស្វាញ មិនព្រមចែករំលែកលាភ-យស-សុខសរសើរឬប្រយោជន៍ព្រមទាំងភាគុភាពនិងសមត្ថភាពដល់គេ

៩ - មាយា មានពុតត្បុតភាក្រក់ ឬបិទបាំងទោសខ្លួន ទំលាក់ទោសទៅលើអ្នកដទៃ ។

១០ - សាឋេយ្យៈ អួតអាង ឬអែបអបបន្លំខ្លួន

១១ - ថម្ភៈ កោងឆបព្រហើន ឬ បះបោរមុខរឹង

១២ - សារម្ភៈ អួតថាគ្រាន់ ឬ ដណ្តើមគ្រាន់លើគូកែតែឯង

១៣ - មានៈ ធំខ្លួន ឆ្មើងកន្ទ្រើង ឬ ក្រអឺតក្រអោង

១៤ - អតិមានៈ មើលងាយគេ ឬ មាក់ងាយមាក់ងោគេ

១៥ - មទៈ ស្រវឹងល្អក់ក្នុងលាភ - យស - សុខ - សរសើរ

១៦ - បមាទៈ ធ្វេសប្រហែស លង់ខ្លួន ភ្លេចស្មារតី ឬប្រាសសតិសម្បជញ្ញៈ ។

ឯហេតុទីពីរបានដល់

អគតិ ៤ គឺៈ

១ - ឆន្ទាគតិ សេចក្តីលំអៀង ឬ យល់មុខព្រោះស្រឡាញ់, ព្រោះគាប់ចិត្ត ។

២ - ទោសាគតិ សេចក្តីលំអៀង ឬ ផ្ទុយព្រោះស្អប់, ព្រោះខឹង ។

៣ - មោហាគតិ សេចក្តីលំអៀង ឬ គិតខុសព្រោះល្ងង់, ព្រោះពុំយល់ខុសត្រូវ ។

៤ - ភយាគតិ សេចក្ដីលំអៀង ឬ ការណាចរណាំចនែបតប់ព្រោះ ខ្លាចបុណ្យខ្លាចអំណាច ឬ ខ្លាចចិត្តគេ ។

ចំណែកខាងហេតុជាតំរប់បានដល់

## ទិដ្ឋិ ឬ សត្រូវធំ ២ គឺ:

១ - ឧច្ឆេទទិដ្ឋិ លទ្ធិមិនជឿស្ថានសួគ៌-នរក មិនជឿបុណ្យ បាប គិតតែឲ្យបានច្រើន បានសប្បាយក្នុងបច្ចុប្បន្ន

២ អត្តទិដ្ឋិ លទ្ធិគិតតែប្រយោជន៍ខ្លួន ពួកគណៈខ្លួន ជាតិខ្លួន មិនគិតដល់ជាតិគេផង ។

ធម៌ដ៏លាមកប៉ុណ្ណោះជាដើម សុទ្ធតែជាធនបំបែកសាមគ្គី ជាមេ បំផ្លាញសាមគ្គី ឲ្យអន្តរាយសាបសូន្យទៅ ។ ហេតុនេះ នាយករបស់ សាសនា ឬមាចរបស់រដ្ឋទាំងឡាយ ត្រូវតែបៀសវាងឲ្យស្រឡះ កុំបណ្ដោយឲ្យកើតមានក្នុងខ្លួន ទើបការបណ្ដុះសាមគ្គីរវាងសាសនិកជន ឬមនុស្សជាតិផងគ្នាឲ្យកើតបាន ។

គ្រានេះ ខ្ញុំស្រាវជ្រាវរកធម៌សម្រាប់បណ្ដុះសាមគ្គី ខ្ញុំឃើញធម៌ជា គ្រឿងធ្វើសាមគ្គីឲ្យលូតលាស់ បំរើនឡើង ។ ទើបកើតប្រស្នាថា: ធម៌អ្វីខ្លះជាគ្រឿងបណ្ដុះសាមគ្គី? សាមគ្គីនឹងលូតលាស់បំរើនឡើងដោយសារ ធម៌អ្វី? ខ្ញុំសូមដោះស្រាយប្រស្នាទាំងនេះ តាមច្បាប់ព្រះពុទ្ធសាសនា

យើងតែម្យ៉ាង បើមិនរកផ្លូវដទៃមកប្រកបផងក៏បាន តែមិនទាំឲ្យយឺតយូរហួសពេលវេលា ។

សាមគ្គីនឹងកើតឡើងបាន ឬសូម្បីប្រេះឆាហើយ នឹងផ្សារគេឲ្យជាប់វិញបាន ដោយការស្រ័យធម៌ច្រើនប្រការគឺៈ ដោយសារសង្គហវត្ថុនិងសារាណីយធម៌ជាដើម ។

## សង្គហវត្ថុមាន ៤ គឺៈ

១- ទានៈ ការឲ្យទេយ្យវត្ថុ ឬចែកអានុភាពនិងសមត្ថភាពឲ្យដល់គ្នានឹងគ្នាតាមការគួរ ។

២ បេយ្យវជ្ជៈ ការពោលពាក្យគួរឲ្យចង់ស្ដាប់ ឬស្រឡាញ់កក់ក្ដៅដោយពាក្យពីរោះចំពោះជនទូទៅមិនរើសមុខ ១ និង ស្រឡាញ់លើកដាស់តឿនប្រាប់ប្រយោជន៍, ប្រាប់ទំលាប់និងសេចក្ដីខុសត្រូវ ។

៣- អត្ថចរិយា ការប្រព្រឹត្តអំពើជាប្រយោជន៍ដល់គ្នានឹងគ្នា ឬធ្វើប្រយោជន៍ឲ្យកើតឡើងដល់ខ្លួនព្រមទាំងអ្នកដទៃ ។

៤- សមានត្តតា ការតាំងខ្លួនស្មើៗ មិនរើសអើង មិនប្រកាន់ខ្លួនដោយជាតិ, ត្រកូល, យសស័ក្តិ, ទ្រព្យសម្បត្តិ ។

## សារាណីយធម៌មាន ៦ គឺៈ

១- មេត្តាកាយកម្ម ការធ្វើដែលត្រូវធ្វើតាមផ្លូវកាយ សុទ្ធតែប្រកបដោយមេត្តា ឬមេត្រីចិត្តដល់គ្នានឹងគ្នា ។

២-មេត្តាវចីកម្ម គឺពួកការដែលត្រូវចាត់ចែងដោយសំដី សុទ្ធតែប្រកបដោយមេត្តា ។

៣-មេត្តាមនោកម្ម អំពើដែលនឹកគិតក្នុងចិត្ត សុទ្ធតែប្រកបដោយមេត្តា ឬមេត្រី ។

៤-លាភៈ ការចែករំលែកលាភ-យស-សរសើរ និងសុខដល់គ្នា ។

៥-សីលៈ ដំណើរមានសណ្ដាប់ធ្នាប់, របៀបរៀបរយ និងសេចក្ដីប្រព្រឹត្តត្រូវគ្នា តែមួយ ។

៦-ទិដ្ឋិ សេចក្ដីយល់ឃើញត្រូវគ្នា ចុះសំរុងគ្នា ឬលទ្ធិត្រូវគ្នា មិនខុសស្ទាគ្នា ។

ធម៌ដ៏ឧត្ដមប៉ុណ្ណោះជាដើម សុទ្ធតែជាមេ ឬជាបច្ច័យឲ្យកើតសាមគ្គី ទាំងជាគ្រឿងផ្សាសាមគ្គីដែលប្រេះឆាហើយ ឲ្យជាប់មាំវិញបាន ។ គួរបុគ្គលជាអាយកទាំងឡាយ ព្រមទាំងសាសនិកជន និងប្រជាជនទូទៅ បណ្ដុះឲ្យមានក្នុងខ្លួន ទើបពេញលក្ខណៈជាមហាបុរស ជាវរបុរស ឬជាបរិស័ទ្យ ជាពលរដ្ឋពិតៗ ដែលនាំឲ្យបានសុខចំរើន ។

សាមគ្គីធម៌ ដែលនឹងមានអាយុជីវិតល្អលាស់ចំរើនឡើងបាន ក៏ព្រោះអាស្រ័យធម៌ ៦ យ៉ាងទៀត គឺ

១ - វីរិយៈ សេចក្ដីព្យាយាមក្លៀវក្លា ។

២ - ខន្តិ សេចក្ដីអត់ធន់ ឬការស៊ូអត់ធ្មត់ចំពោះការងារ ។

៣ - សច្ចៈ សេចក្ដីពិតស្មោះត្រង់ដល់គ្នានឹងគ្នាមិនក្បត់ចិត្តគ្នា ។

៤ - អធិដ្ឋានៈ សេចក្ដីតាំងខ្លួនដោយឧបាយបញ្ញា ។

៥ - មេត្តា សេចក្ដីរាប់អានគ្នាដោយស្និទ្ធស្នាល ។

៦ - បរិច្ចាគៈ ការចែករំលែក ដោយសង្គ្រោះ ឬដោយការបូជាគុណ ។

ធម៌ទាំង ៦ យ៉ាងនេះ ទុកដូចជាអាហារចំណីសម្រាប់ចិញ្ចឹមសាមគ្គីឲ្យរីកធាត់ធំមាំមួន ពុំនោះទុកដូចជាជីជាតិសម្រាប់ស្រោចស្រង់ឫសព្រឹក្សសាមគ្គី ដែលទើបនឹងដុះដាលលូតលាស់ចំរើនឡើង ។ ឯសាមគ្គីនោះ បើប្រាសចាកធម៌ទាំងនេះហើយ ក៏រមែងរលត់លោយស្វិតស្រពោនទៅ ឬក៏បែកបាក់រលាយបាត់ទៅ ដោយឆាប់រហ័សពុំខាន ។

ព្រោះហេតុនោះ សាធុជនអ្នកមានបំណងល្អចំពោះសាសនា, ចំពោះប្រទេសជាតិរបស់ខ្លួន ឬចំពោះលោកទាំងមូល ចង់ឲ្យបានសន្តិសុខ ចំរើនរុងរឿង ត្រូវតែជំរុញខ្លួនឲ្យតាំងនៅក្នុងគុណធម៌ទាំងអស់ ដូចរៀបរាប់មកជាសង្ខេបប៉ុណ្ណេះ ទើបសាមគ្គីធម៌ — សីលធម៌ — វិន័យធម៌ - យុត្តិធម៌នឹងដុះដាលលូតលាស់ឡើងវិញ ហើយនឹងចំរើនរុងរឿងតទៅ ។

ឆ្លើយដោយខ្លីថា ព្រះពុទ្ធសាសនាដែលផុតរលត់បាត់បង់ពីប្រទេសឥណ្ឌា ក៏ព្រោះតែពុទ្ធបរិស័ទបែកសាមគ្គី ទៅជាគណៈនិកាយយ៉ាងច្រើនដល់ទៅ ១៨ និកាយ ប្រទេសដទៃក្នុងពុទ្ធសម័យ មានរបៀបគ្រប់គ្រងថា គណរដ្ឋ ឬ ហៅថា សាធារណរដ្ឋ សម័យមុនណាអាស្រ័យសាមគ្គីធម៌ជាហេតុ ទើបក្រុងវេសាលី ដែលពួកវជ្ជីរក្សាដែននោះ ទៅជាក្រុងរុងរឿងបំផុត តាមតែព្រះពុទ្ធជាម្ចាស់ទ្រង់ប្រដៅទីឃនិកាយសូត្រ ឈ្មោះពាក្យហោកនិកា តាំងទ្រង់ព្យាករណ៍ថា បើអ្នកដែនរដ្ឋនៅតែមានសាមគ្គី ប្រព្រឹត្តតាមអបរិហានិយធម៌នេះ ដែនរដ្ឋនោះនឹងចំរើនរុងរឿងឥតឈប់ ឥតមានប្រទេសណាទៅលុកលុយបានឡើយ ។ តែសម័យឥឡូវ អ្នកដែនរដ្ឋបែកសាមគ្គីគ្នា ទៅជាពួកជាគណៈ បៀតបៀនកាប់សម្លាប់តែគ្នាឯង មិនយូរប៉ុន្មានក៏ត្រូវអ្នកដែនសហរដ្ឋមគធៈលើកពលទ័ពទៅលុកឆ្មក តាំងតែពីនោះ ក៏រលត់បាត់ឈ្មោះពីដែនដីលោកហូតដល់សព្វថ្ងៃ នេះព្រោះតែបែកសាមគ្គី ។

បើតាមផ្លូវធម៌វិញ សូម្បីអរិយមគ្គប្រកបដោយអង្គ ៨ ដែលជាធម៌ជាទីខ្ពស់ ក៏គង់តែត្រូវរួមគ្នាជាសាមគ្គី ទើបអាចកាត់ផ្ដាច់កិលេសបាន ឥតមានអរិយមគ្គណាមួយ អាចចេញមុខតាមតែឯង ទៅកាត់ផ្ដាច់ប្រហារកិលេសបានឡើយ ។

ព្រោះហេតុដូចបរិយាយមកនេះ ទើបគួរតែនាំគ្នារួមសាមគ្គីឡើង រក្សាជនជាតិជាមួយគ្នា ឬរួមកាន់សាសនាជាមួយគ្នា ហេតុដល់លោកទាំងមូលដែលជាមនុស្សជាតិដូចគ្នា ទើបសេចក្ដីសុខសេចក្ដីចំរើនដែលជាកំពូលនៃសេចក្ដីប្រាថ្នា ទើបកើតមានឡើងយ៉ាងពិតប្រាកដពុំខាន ។

សូមអស់លោក-អ្នកស្ដាប់បានឮ កំណត់ចាំទុកហើយប្រតិបត្តិតាមប្រយោជន៍តាមគួរដល់អធ្យាស្រ័យចុះ ។ សំដែងមកក្នុងសាមគ្គីធជាចប់តាមកាលវេលាតែប៉ុណ្ណេះ ។

សូមសុខសួស្ដីសិរីវឌ្ឍនាភាព កើតមានដល់លោកអ្នកស្ដាប់ អស់កាលជាអង្វែងទៅហោង ។

ព្រះមហា រស់-កោ ( កោវិទត្ថេរ )

ពន្លឺអាស៊ីទ្វីប

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

(៣៥៣)

គ្រានោះ មានអ្នកក្រាបបង្គំទូលថា «បពិត្រព្រះអង្គដ៏ចំរើនក្សេម-ក្សាន្ត, មានព្រះនគរ មានវត្តអារាម, សួនច្បារទឹងនៃព្រះបុរៈ មានពល មានជ្រោះជ្រលងជងភ្នំ មានពលសេនា មានព្រៃញឹក មានពលសេនា យ៉ាងធំជាបន្ទាយរក្ខ ជាចំនួនប្រែនគឺព្រះរាជអាណាចក្ររបស់ព្រះបាទពិម្ពិសារ ហើយនៅទីបំផុតជាទីពលដ៏ធំទូលាយរបស់លោក ដែលមានមនុស្សរាប់កោដិលានអាស្រ័យនៅ» ។

ព្រះសិទ្ធត្ថៈ ត្រាស់ថា «តែរហើយ ចូរប្រាប់នាយឆន្នៈឲ្យត្រៀមទឹមរថសេះយើង វេលាព្រឹកនេះថ្ងៃត្រង់ យើងនឹងទៅមើលរបស់ដែលមាននៅខាងក្រៅព្រះរាជវាំង» ។ ទើបមានអ្នកទៅក្រាបបង្គំទូលព្រះរាជបិតាថា «បពិត្រព្រះអង្គ, ព្រះរាជបុត្ររបស់ព្រះអង្គមានព្រះបំណងចង់ឲ្យទឹមព្រះរាជរថចេញទៅនៅវេលាព្រឹកនេះថ្ងៃត្រង់ ដើម្បីចង់ទតព្រះនេត្រមនុស្សជាតិ» ។

ព្រះរាជាមានព្រះឱង្ការថា «អើ ដល់ពេលដែលគេនឹងគួរឃើញហើយ តែចូរចាត់ការប្រកាសដល់ចណ្ដាលស្ត្រូវតាំងពួនឲ្យគាត់តែងព្រះនគរឲ្យរុងរឿង កុំឲ្យមានបុគ្គលណាមួយដែលនាំឲ្យកើតសោក

ស្ងប់ចិត្ត  កុំឲ្យមានមនុស្សខ្វាក់ខ្វែកឬកំបុតជើងណាមួយ  មនុស្សឈឺ មនុស្សមានអាយុច្រើន  មនុស្សកើតឃ្លង់  មនុស្សពិការទាំងឡាយ កុំឲ្យចេញមុខឲ្យសោះជាដាច់ខាត »  ហេតុដូច្នោះ  ទើបគាត់ឲ្យមាន បោសសំអាតផ្លូវថ្នល់  ពួកអ្នកខ្លះរែកខ្សាច់ក៏រែកដីកកស្រោបថ្នល់គ្រប់ ១ អន្ទើ  ពួកស្រីមេផ្ទះក៏បាចសាចពោយលំអិតបន្ទន់ក្រហមលើផណើ ទ្វារផ្ទះ របស់ខ្លួន  ប្រដាប់ប្រដាកម្រង់ផ្កាថ្មី  តាំងជាំ ជារដើមម្រះព្រៅភាងមាត់ ទ្វារផ្ទះ  រូបហាបថ្នាំពណ៌នៅតាមជញ្ជាំងផ្ទះ  ក៏លាប បនដួមធុល ជាថ្មី,  បណ្ដាដើមឈើក៏គាត់ដោតទង់ប្រដាប់ពេញដើម,  រូបផាទី គោពេ  ក៏គាត់គារថៃមាសជាថ្មី  នៅផ្លូវបំបែករូបសុរិយទេពធីងទេវរូប ជីសក្តិសិទ្ធិសិនក្ដីថ្វាសិតលើបង្គំដោយប្រការដូចនេះឯង  ព្រះឧគរហាក់ ដូចជាទីក្រុងនៃអាណាចក្រដ៏ក្សេមក្សាន្ត  មានគោស្រែកប្រកាសទៅគ្រប់ ផ្លូវថ្នល់  ព្រមទាំងទូងស្គរកេយគងគោង  ហើយស្រែកយ៉ាងខ្លាំង ១ ថា » ចូរជនទាំងឡាយចាំស្ដាប់,  ព្រះករុណាមានព្រះបរមរាជឱង្ការដម្រាស់ថា ថ្ងៃនេះកុំឲ្យមានសភាពជាទីសោកសៅឲ្យប្រាកដចេញមកយ៉ាងដាច់ខាត, កុំបណ្ដោយឲ្យមនុស្សខ្វាក់ខ្វែក  ជើងខ្វិន  មនុស្សចាស់  មនុស្សកើត ឃ្លង់  និងមនុស្សពិកពិការណាមួយចេញមកឲ្យឃើញជាក់ស្ដែងយ៉ាង ដាច់ខាត  ហើយហាមកុំឲ្យអ្នកណាមួយបូជាសពខ្មោចយកសពចេញក្នុង

ថ្ងៃនេះវេកបវល់ពេលព្រលប់ ទាំងនេះជាព្រះរាជនត្តារបស់ព្រះបាទសុទ្ធោទនមហារាជ ។

កាលបើមានបន្ទាប់ដូច្នេះ គ្រប់យ៉ាងគ្រប់ប្រការ សុទ្ធសឹងនាំឲ្យកើតកើនចំរើនបត្តុប្រាសាទ បណ្តាគេហស្ថានទាំងពួង សឹងប្រដាប់ប្រដាពាសពេញទាំងក្រុងកបិលពស្តុ, នាពេលព្រះសិទ្ធត្ថរាជកុមារស្តេចប្រពាតដោយព្រះរាជរថ ដ៏ឆើតឆាយពណ្ណរាយ ទឹមសេះតូសំបុរសដូចជាហិមៈ, ដែលឃ្មោងត្រដូសពោនទាំងទីងទីមធំ ឡាក់លាបម្រ័ក្សណ៍ ការរីករាយរបស់ប្រជាជនដែលស្រែកហោគឹកកងទទួលអំណរព្រះរាជឱរស ធ្វើឲ្យកើតភាពជាទីទស្សនាយ៉ាងក្រៃលែង ព្រះសិទ្ធត្ថទ្រង់សប្បាយព្រះទ័យ ដែលបានទ្រង់ទតឃើញហ្វូងប្រជារាស្ត្រស្មោះត្រង់របស់ព្រះអង្គតាក់តែងកាយសម្រាប់ថ្ងៃបុណ្យរីករាយសប្បាយ ហាក់ដូចជាយល់ថា ការមានជីវិតរស់នៅជាការប្រពៃ ទើបមានព្រះឱង្ការថា «លោកនេះល្អណាស់តើ, យើងគាប់ចិត្ត ហើយបណ្តាជនទាំងនេះសុទ្ធតែមិនមែនជាស្តេចទេ តែសុទ្ធតែស្រស់បស់ គួរស្រឡាញ់ ហើយដែលគួរអាណិត គឺ ពួកកតិនដែលធ្វើការថែរក្សាចៅចាំផ្ទះ ចុះយើងបានធ្វើប្រយោជន៍អ្វីឲ្យគេទាំងនេះ ទើបគេរីករាយសប្បាយ? ចុះពួកក្មេងទាំងនេះដឹងបានដូចម្តេចថា យើងស្រឡាញ់គេ? អាណិតនាំយកសាកិយៈក្មេងតូចៗ ដែលបោះផ្កាមកឲ្យយើងនោះឡើងមកលើរថជាមួយ

ខឹង យើងផងចុះ, ប្រសើរណាស់ដែលបានឡើងគ្រងរាជ្យនៅកងជាទីនេះ, ជាសេចក្ដីសុខក្សេមណាស់តើ!, ប្រសិនបើប្រជាជនទាំងនេះទទួលអំណរសោះ ព្រោះហេតុតែយើងមកនៅកណ្ដាលហ្វូងគេ, របស់ទាំង-ឡាយទាំងពួងឥតប្រយោជន៍ដល់យើងអ៊ីម្ល៉េះទេ ;ប្រសិទបើថណ្ដាជុំតូចៗពោរពេញទៅដោយការីកាយក្សេមក្សាន្ត ល្មមបំពេញព្រះឧទរយើងឲ្យពេញទៅដោយសេចក្ដីត្រេកត្រអាលបាន, ឆន្នៈ, បរទៅឲ្យឆាប់ៗឡើង! ចេញទៅឲ្យយើងបានឃើញលោកយ៉ាងត្រកាលដែលយើងមិនទាន់ដឹងជានៅមានប្រទេសទៀត។ ដូច្នោះ នាយឆន្នសារថីក៏បរព្រះរាជរថនាំព្រះរាជកុមារចេញទៅកណ្ដាលហ្វូងជនដែលកំពុងរែករាយសប្បាយនាំគ្នាចៀសផ្លូវព្រះរាជរថ, មានមនុស្សខ្លះរត់ទៅខាងមុខគោះបោះផ្កាម្រិញផ្កាថ្វាយ ខ្លះលូកស្លាបផ្អៀងទីរនោះសកកង, ខ្លះទៀតក៏នាំបាយទឹកនំមកថ្វាយហើយកល់ៗគ្នា ស្រែកឡើងបញ្ចេញទាន-វាចាថា " ជ័យោ, ជ័យោ ក្សត្រថ្លៃរបស់យើង" ។ នៅខណៈដែលថ្នល់គ្រប់ៗផ្លូវ កំពុងដេរដាសដោយមុខមាត់ជ័រការ ទឹងសភាពនៃសេចក្ដីក្សេមក្សាន្តតាមព្រះរាជដំណើររបស់ព្រះរាជានោះ ស្រាប់តែមានសម្បយាបកនញ្ញាស់ម្នាក់រូបកន្លែងព្រៃ ក្នុងក្រឡើងក្រឡាប់កង់ស្រម៉កដោយញើសក្អួល ក្រោកចេញពីរណ្ដៅបំបាំងខ្លួន រូបប្រឹងដើរទទ្រេតទទ្រោតមកកណ្ដាលថ្នល់ សម្បើមនះពុលភាពណាស់ ចាស់ណាស់

ស្បែកជ្រួញជ្រីវដោយអំណាចកំដៅនៃថ្ងៃអាទិត្យ ស្បែកដណ្តប់ឆ្អឹង ខ្នងកោងដោយកាលដែលទ្រាំមកយូរយារដោយអនេកចិត្ត គ្រប់តែក្លួនមានសម្បុរ ដាំខ្មៅដោយអំណាចទឹកភ្លៀងហូរ ព្រោះអស់កាលយូរមកហើយ ភ្នែកស្មឹក ស្មុក ឆ្ពាមជ្រុះសព្វខ្ទង់ អង្គុលីកាយញ័រចំប្រប់ដោយព្យាធិ ទង សេចក្តីភ័យខ្លាចដៃ មើមខ្នុង ឃើញហ្វូងជនកំពុងទ្រោលយើងខ្ពុះ ដៃស្គម ខ្វាន់កាន់ច្រត់លើឈើច្រត់ កញ្ចាស់ស ម៉ៅចចប់ដើរ ញញ័រកញ្ជ័រ ទាំងសង់ខាង ហើយដៃម្ខាងទៀតច្រាបចចប់ធ្មេញឆ្អឹងជំនីរដែលគាត់ដកដង្ហើម ចេញពុះដោយលំបាក សូមនេះតាំងស្រែកស្មូថា «លោកម្ចាស់អើយ មេត្តាជាងតានជង ព្រោះខ្ញុំបាទទឹងស្លាប់កនៃថ្ងៃនេះឬស្អែកនេះហើយ» ថាហើយក៏ក្អកបញ្ចេញឥតឈប់ៗ ហើយលាហុចដៃទៅ, ភ្នែកព្រឹមៗហើយ ញ័រគ្រោកសរសៃហើយស្រែកទៀតថា «ជាកំពាក់ៗ ព្រះគុណអើយ! បណ្តាខ្ញុំដែលហែហមវោមពេមតាមហែស្តេច កំនាំគ្នាចាប់គាត់ស្មុស កន្ទ្រាក់ទៅលើផ្លូវថ្នល់ស្រែកថា «ព្រះករុណាស្តេចយាងមក មើល មិនឃើញទេឬអី ចូររំលះទៅផ្ទះរបស់គាត់វិញទៅ! តែព្រះសិទ្ធត្ថមាន ព្រះបន្ទូលថា «លែងគាត់ទៅ! លែងគាត់ទៅ! នាយឆន្នៈ! គួរសង្វេគ លោកអ្នកដូចជាមនុស្សឃើញដែរ តែខុសគ្នាត្រង់ដែលមានខ្នងកោងគាត យ៉ាង មុខគួរឲ្យអាណោចអធ័ម មានអាការគ្រាក់ឆ្អើម ចុះមានមនុស្ស ដែលកើតមកមានសភាពដូច្នេះដែរឬទេ! សំដីដែលគាត់និយាយថា

ខ្ញុំនឹងស្លាប់ក្នុងថ្ងៃនេះឬថ្ងៃស្អែកនេះហើយ នោះសំដៅយកថា ប្រហែលជាគាត់មិនបានបរិភោគទេ បានជាគាត់មានឆ្អឹងលៀនចេញស្រួចៗមកដូច្នោះ។ អកុសលកម្មដែលមកប៉ះពាល់ដល់រូបសត្វមុខគួរឲ្យវេទនានេះ។ ទើបនាយសារថីក្រាបទូលសួរព្រះរាជកុមារថា «បពិត្រព្រះអង្គដ៏ទ្រង់ព្រះគុណធម៌ដ៏ប្រសើរ នេះគឺមនុស្សចាស់ កាលពី ៨០ ឆ្នាំមកហើយនោះ ខ្លួនគាត់នៅក្រមុំ ក្មេងនៅខ្ចី កងឆាយនៅថ្លូរផង ឥឡូវនេះអំណាចចាស់ជរាធ្វើឲ្យលោហិតដែលចិញ្ចឹមកងកាយហួតហែងទៅហើយ អូសយកកំឡាំងពលរបស់គាត់ឲ្យថយទៀតក្រោយទៅផង ធ្វើឲ្យសតិសម្បជញ្ញារបស់គាត់សាបសូន្យទៅផង, ប្រេងក្នុងបញ្ចេន្ទ្រិយរបស់គាត់បានផុតអស់ទៅហើយ របស់ដែលសេសសល់គឺជីវិតរបស់គាត់គ្រាន់តែជាពន្លឺព្រឹមៗ មុននឹងរលត់ផុតទៅតាមធម្មតានៃផលដែលជាទីបំផុតរបស់ជីវិត ចុះព្រះអង្គទ្រង់យកព្រះទ័យទុកដាក់ធ្វើអ្វី? ព្រះរាជកុមារទើបមានព្រះបន្ទូលថា ចុះអ្នកឯទៀតៗឬមនុស្សគ្រប់រូបតែងតែដូចេះដូចគ្នាឬទេ? ឬ ១ មានចំនួនតិចទេ មានចំនួនដូចយាបតស្ងមនោះ? នាយឆន្នៈទូលស្នងព្រះតម្រាស់ថា «បពិត្រព្រះអង្គដ៏ទ្រង់ញាណសុខុម, មនុស្សគ្រប់រូបដែលកើតមកនេះតែងមានចំនួនដូចជាគាត់នេះទាំងអស់ ប្រសិនបើអ្នកទាំងនោះ មានជីវិតរស់នៅបានយូរៗ

(នៅមានត)

# បុណ្យឈាបនកិច្ចសពអ្នកអាចារ្យហ៊ិន - សុជ

## វត្តពោធិ៍ពល ឃុំស្វាយពោ ស្រុកសង្កែ ខេត្តបាត់ដំបង

ភិក្ខុ សួន - សុរិន្ទ វរិវង្សោ វត្តលង្កា ក្រុងភ្នំពេញ រៀបរៀងតាមទម្រង់ការរបស់
ព្រះតេជព្រះគុណព្រះមុនីកោសល មេគណខេត្តបាត់ដំបង ។

---

អ្នកអាចារ្យហ៊ិន - សុជ ជាបុរសម្នាក់មានឧបការៈច្រើនដល់វត្តពោធិ៍ពល តាំងអំពីគង់កាលជាបព្វជិតរហូតដល់ត្រឡប់ទៅជាគ្រហស្ថ ដោយអ្នកអាចារ្យនេះខំប្រឹងឥតធុញទ្រាន់ ក្នុងការចាត់ចែងធ្វើឲ្យកើតសេចក្ដីចម្រើនខាងការសិក្សានិងការលូតលាស់ផុះផាលគ្រប់យ៉ាងក្នុងវត្តពោធិ៍ពល អ្នកអាចារ្យនេះដល់ពេលក៏ចូលមរណកាលទៅ មកដល់ឥឡូវនេះប្រមាណ ៤ ឆ្នាំហើយ ពុំទាន់បានធ្វើបុណ្យឈាបនកិច្ចនៅឡើយ ។

លុះមកដល់ថ្ងៃ ៤ ១ ៨ ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ ត្រូវនឹងថ្ងៃ ( ៣១ - ៤ - ៤៩ ) ក្រុមញាតិមិត្តនិងសិស្សានុសិស្សព្រមទាំងភរិយាអ្នកអាចារ្យ ហ៊ិន - សុជ មានព្រះតេជ - ព្រះគុណព្រះមុនីកោសល មេគណខេត្តបាត់ដំបងជាប្រធាន បានចាត់ចែងធ្វើបុណ្យឈាបនកិច្ចសពចំនួន ៧ យប់ ៧ ថ្ងៃយ៉ាងឧឡារិក ដើម្បីសំដែងសេចក្ដីកតញ្ញូកតវេទិតាចំពោះសពអ្នកអាចារ្យ ហ៊ិន - សុជ ដូចមានរបៀបរៀបចំតទៅនេះ

# របៀបរៀបចំ

១- នៅក្លោងទ្វារខាងមុខ មានឆាក់តែងដោយក្រដាសជាលំអផ្សេងៗ ខាងស្ដាំដោតទង់ជ័យខ្មែរ ខាងឆ្វេងដោតទង់ជ័យបារាំង ហើយបិទសំពត់ស ១ ផ្ទាំងសរសេរអក្សរថា "ខុំដូសកុសលផលបណ្ឌិតសុជ»

២- មុខព្រះវិហារមានរោង ២ ខាងស្ដាំរោងក្ដក់ថែង ខាងឆ្វេង រោងភ្លេងពោធិ៍កល លើខឿនព្រះវិហារមានរោង ៤ រោងធំវីសទីរោង សង្ឃ ខាងទិសឧត្ដរ រោងកណ្ដាល ខាងទិសអគ្នេយ៍ រោងក្រៅ ខាងទិសឦសាន រោងភ្ញៀវកុងទីរោងស៊ុំកើខាងទិសពាយ័ព្យ រោងទាំង ៦ នេះរោងមួយៗ មានបណ្ដោយ ៦ ម៉ែត្រ ទទឹង ៣ ម៉ែត្រ មានតែង ដោយស្លឹកឈើស្រស់ៗ និងដុតបន្ទៀងគ្រប់ទិសទីព្រោងព្រាត ហើយ តាំងបុកណាគ្រឿងរគសម័យបុរាណៗ សំរាប់ជូនមើលកំសាន្ត ។ ខាងត្បូង សាលាបុណ្យមានលិចបម្រុងកាមានរោង ២ រោង ១ សំរាប់ដាំស្ល រោង ១ ទៀតសំរាប់រៀបចំភោជនាហារទទួលភ្ញៀវ ។ ខាងកើតព្រះវិហារខាងជើងភ្នំ នៅលើចេតិយ៍១មានវេទាដោយក្រដាសផ្សេងៗ ហើយតាំងបុកណា-គ្រឿងរគសម័យបុរាណៗ ជូនមើលកំសាន្តដែរ ។

៣ — ខាងជើងចេតិយ មានរោង ១ សំរាប់ពួកល្ខោន «ភ្លេងពិទក្ស» លេងជូនមើលកំសាន្ត ។

៤ — ខាងកើតមានតាក់តែងរោង ១ សំរាប់ជាពន្លាកក់ មានបណ្ដោយ ៨ ម៉ែត្រ ទទឹង ៤ ម៉ែត្រ ក្នុងរោងនោះសង់បង់រាំងសំពត់ព័ទ្ធជុំវិញហើយតែងស្លឹកឈើស្រស់មានពណ៌ផ្សេង ៗ ស្រោបសសរទ្រូង ផ្ទៃផ្ទាំងតែងលំអទ្វារ មានផ្កាបង់រំយោលព្យួរសំយុងចុះ ត្រង់បន្ទោះតែងៗ លៃង ត្រង់ច្រកចូលមានតែងស្លឹកឈើស្អិតស្អាងប្រដាប់ជាសុំពារ ហើយដោតទង់ប្រាសាទ (ទង់ជាតិ) និងទង់បាក់ងមដើម្បីជាកិត្តិយស ។

៥ — ខាងត្បូងមានធ្វើបាក់សំពត់ស ១ យ៉ាងស្អាត សំរាប់ទទួលមន្ត្រីខ្មែរ-បារាំង ។

៦ — បាក់ ១ តមខាងត្បូងទៀត សំរាប់ទទួលក្រុមមួយជំនួយ

៧ - កុដិទាំងអស់សុទ្ធតែរៀបចំដោយគ្រឿងលំអផ្សេង ៗ

សាលាគណ សំរាប់ទទួលសម្តេចព្រះសុគន្ធាធិបតីសង្ឃនាយកគណៈធម្មយុត្តិនិងព្រះបាឡាត់ ធម្មមុនី (ល័) កុដិព្រះតេជ-គុណព្រះមុនីកោសល សំរាប់ទទួលព្រះតេជ-គុណព្រះមហាសុមេធាធិបតី សង្ឃ-នាយកគណៈមហានិកាយ ព្រះតេជ-គុណព្រះពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ព្រះតេជ-គុណព្រះពុទ្ធវង្សអធិបតីក្រុមជំនុំប្រែព្រះត្រៃបិដក ព្រះតេជ-គុណព្រះសាសនមុនីឧង ចៅអធិការវត្តគោនា-រាម ។ ធម្មទ្រីសំរាប់ទទួលឥទ្ធគណស្រុកទាំង ៨ កុដិឯទៀតសំរាប់ទទួលលោកគណនុក: ។ ឯសាលាបាលីរងនឹងធម្មសភាសំរាប់ទទួលពួកឧបាសកឧបាសិកាដែលមកអំពីចម្ងាយ ។

# របៀបចាត់ការក្នុងវត្ត

ដើម្បីឲ្យស្រួលបួលក្នុងការចាត់ចែងបុណ្យឈាបនកិច្ចនេះ ព្រះរាជ-គណៈ ព្រះមុនីកោសល មេគណ ខេត្តបាត់ដំបង បានចាត់មនុស្សជាក្រុមៗ រួមទាំងអស់ ១៦ ក្រុម បុរស ៩ ក្រុម ស្ត្រី ៧ ក្រុម ដូចមានរបៀបតទៅនេះ

## បុរស ៩ ក្រុមគឺ

| | | |
|---|---|---|
| ទី ១ — ក្រុមហេរញ្ញិក | មានលោកសុម-ព៉ន់ | ជាអធិបតី |
| ទី ២ — ក្រុមបដិសណ្ឋារៈ | — ហ៊ិន-ប៊ុន-កាក់ | — |
| ទី ៣ — ក្រុមភេសជ្ជៈ | — អួនថៃ | — |
| ទី ៤ - ក្រុមមហោស្រព | មាននាយសម័យ | ជាអធិបតី |
| ទី ៥ - ក្រុមឃោសនាការ | " ព្រះសមុហជួន-ឡឿន | " |
| ទី ៦ - ក្រុមសង្ឃការី | " អួចទេត | " |
| ទី ៧ - ក្រុមកណ្ណាគារិក | " ភិក្ខុលៀម | " |
| ទី ៨ - ក្រុមបូជាសព | " ជានយុត | " |
| ទី ៩ - ក្រុមពិសេស (មើលការខុសត្រូវ) | មានវិន័យធរយ៉ែម | " |

## ស្ត្រ ៧ ក្រុមនោះគឺៈ

ទី ១ ក្រុមមេចុងភៅ មានវៃយ៉ន់ ជាអធិបតី

ទី ២ - ក្រុមធ្វើបង្អែម " " ធម "

ទី ៣ - ក្រុមបដិសណ្ឋារៈ មាន អ្នកឡាប "

ទី ៤ - ក្រុមលាងចាន " អ្នកមុត "

ទី ៥ - ក្រុមមាលាការី " យាយអ៊ិក "

ទី ៦ - ក្រុមស្វាធុរី " យាយលាប់ "

ទី ៧ - ក្រុមពិសេស " អ្នកជូ "

## កម្មវិធី

១ - នៅថ្ងៃ ៤ ១ ៥ ឆ្នាំជូតសំរិទ្ធិស័ក ត្រូវនឹងថ្ងៃ (៣០-៤-៤៩) វេលាម៉ោង ៧ កន្លះព្រឹក លើកសពដំកល់លើហែម និមន្តភិក្ខុសាមណេរ ១០០ រូប បង្សុកូល ហើយក្រុមញាតិមិត្រនឹងសិស្សានុសិស្សព្រមទាំងករិយា ដង្ហែសពអំពីទីស្នានមកដំកល់លើគ្រឿងជាន់នៅទីសាលាធម្មសភាវត្តពោធិ៍វាល មានភ្លេងសង្កៀត (គងស្គរ) ប្រគំជូនសព ដល់ម៉ោង ១១ ថ្វាយចង្ហាន់បិណ្ឌបាតដល់ព្រះសង្ឃ ១០០ រូប វេលាម៉ោង ២០ ចំរើនព្រះបរិត្ត ហើយនិមន្តធម្មកថិក ២ រូបសំដែងធម្មទេសនាបុប្ផា វិសជ្ជនា លុះចប់និមន្តព្រះសង្ឃ ៨ រូបសូត្រព្រះអភិធម្ម ៗ

២ - ថ្ងៃ ២ កើតទឹង ៣ កើត  មានប្រគេនយាគូព្រឹក  ថ្ងៃត្រង់ ប្រគេនចង្ហាន់បិណ្ឌបាត  ល្ងាចចំរើនព្រះបរិត្ត  ទេសនា  សូត្រព្រះ-អភិធម្មដូចថ្ងៃមុន ។

៣ - ថ្ងៃ ៤ កើតត្រង់ទឹងថ្ងៃ ២ - ៤ - ៤៩ ព្រឹកប្រគេនយាគូ  ថ្ងៃត្រង់ប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះសង្ឃ ១០០រូប  វេលាម៉ោង ១៩ រំកិលសពដាក់លើរថយន្ត  ប្រដាប់តាក់តែងដោយក៏ផ្កាស្រស់គុជប្រទីប ផ្កាលាក្ខីព្រានព្រាតនាំសពទៅដំកល់នៅទីវត្តពិពិប ។

(នៅមានត)

អំពីតាំងចៅអធិការនិងគ្រូសូត្រថ្មី

(តមក)

សញ្ញាប័ត្រលេខ ១៧៧ ចុះថ្ងៃ ៦ ៨ ៩ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូផាត់-នៅ នាមតាយា វឌ្ឍបញ្ញោ កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តកោះផាល ឃុំគងជ័យ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ១៧៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូសៅ-ចេត នាមតាយា ព្រហ្មកេត្ត កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១៣ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ២០២ ចុះថ្ងៃច័ន្ទ ៣ រោច ខែស្រាពណ៍ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ណុប-ប៊ុន នាមតាយា ពុទ្ធញ្ញាណ កើតឆ្នាំច អាយុ ២៧ វស្សា ៦ ជាចៅអធិការវត្តព្រៃល ឃុំជម្ពូ ស្រុកកោះសូទិន ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ២០៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុន-ចេង នាមតាយា កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តព្រៃល ឃុំជម្ពូ ស្រុកកោះសូទិន ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ២០៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យល់-ចន នាមតាយា សំវរកេត្ត កើតឆ្នាំខាល អាយុ ២៣ វស្សា ៣ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ២០៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទិ-ពង់ នាមឆាយា សុវណ្ណកេរ កើតឆ្នាំខាល អាយុ ៣៥ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តពោធិមាស ឃុំអំពិលតាពក ស្រុកកោះសូទិន ខេត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ២០៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឧទ្ទកេរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ៨ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ២០៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សេង-ឡុងអាន នាមឆាយា ឧទ្ទសរ កើតឆ្នាំជូត អាយុ ៧៣ វស្សា ៥១ ជាចៅអធិការវត្តកណ្តាលកោះខាងជើង ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ២០៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពង់-ទុយ នាមឆាយា ឧទ្ទវិជ័យ កើតឆ្នាំថោះ អាយុ ៧០ វស្សា ៤៩ ជាគ្រូសូត្រស្តាំ វត្តកណ្តាលកោះខាងជើង ឃុំ-ស្រុកកោះសូទិន ខេត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ២០៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឯក-ឌុប នាមឆាយា សុវណ្ណជោត កើតឆ្នាំថោះ អាយុ ៧០ វស្សា ៤៩ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្រដដែល ។

សញ្ញាប័ត្រលេខ ២១០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញ៉ឹក-យូរ នាមឆាយា សីលធម្ម កើតឆ្នាំមមែ អាយុ ៦២ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្តដំណាក់ព្រីង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ២១១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ណាវ-សន នាមឆាយា ពុទ្ធប្បញ្ញោ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៨ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២១២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ក្រាក់-ជា នាមឆាយា បញ្ញាកេសរ កើតឆ្នាំពុទ្ធសករាជ ២៤៦១ អាយុ ៥០ វស្សា ៣០ ជាចៅអធិការវត្តត្រាង ឃុំតាឯក ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ២១៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សេង-ហង់ នាមឆាយា សុវណ្ណជោត កើតឆ្នាំរកា អាយុ ២៩ វស្សា ៩ ជាចៅអធិការវត្តកោះខ្សាច់ទន្លា ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ២១៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ច័ន្ទ-ព្រំ នាមឆាយា ធម្មជោត កើតឆ្នាំរកា អាយុ ៦១ វស្សា ២០ ជាចៅអធិការវត្តសុវណ្ណគិរី ឃុំថែប ស្រុកថែប ខេត្តកំពង់ធំ ។

(មានត)

# សេចក្ដីជូនដំណឹង

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ សូមជូនដំណឹងដល់អស់លោកអ្នកជាវទស្សនាវដ្ដី «កម្ពុជសុរិយា» សូមជ្រាប ។

ហេតុដែលទស្សនាវដ្ដី «កម្ពុជសុរិយា» យឺតយូរមិនបានផ្សាយចេញតាមកំណត់រៀងរាល់ខែនេះ មិនមែនមកពីពុទ្ធសាសនបណ្ឌិត្យ បណ្ដែតបណ្ដោយឬបង្អែបង្អង់ឲ្យយឺតយូរដោយប្រការណាមួយឡើយ ។ ឯហេតុដែលយឺតយូរកន្លងមកជាច្រើនខែនេះ គឺមកតែពីរោងពុម្ពព្រះរាជទ្រព្យ មានការច្រើនពេក មិនអាចនឹងទទួលធ្វើការឲ្យយើង បានរួសរាន់ទាន់កំណត់រៀងរាល់ខែប៉ុណ្ណោះ ។

ហេតុនេះ ពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសអស់លោកអ្នកជាវ ដោយគោរព ហើយសូមបញ្ជាក់ថាពុទ្ធសាសនបណ្ឌិត្យ នឹងខំប្រឹងបោះពុម្ពផ្សាយទស្សនាវដ្ដីនេះត្រាតែគ្រប់ចំនួន ជូនអស់លោកអ្នកជាវ ពុំបានខាន ។

ដល់ចូលទៅ ក្នុងឆ្នាំ ១៩៥០ យើងនឹងរកមធ្យោបាយដើម្បីធ្វើឲ្យទស្សនាវដ្ដីរបស់យើង អាចចេញផ្សាយបានតាមកំណត់រៀងរាល់ខែ ។

អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។

IMPRIMERIE ROYALE